១៥៥

CEDAC

# កសិករ

*Farmer*

ទស្សនាវដ្តីប្រចាំខែ
ឆ្នាំទី ៦ លេខ ០៨ សីហា ២០០៤

## ទស្សនាវដ្តីសំរាប់អភិវឌ្ឍន៍កសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា

## Magazine for the Development of Family Agriculture in Cambodia

- បទពិសោធន៍រៀបចំកសិដ្ឋានពហុប្រយោជន៍
- បទពិសោធន៍ដាំត្រសក់ទ្រើង
- បទពិសោធន៍ទាក់ទាញត្រីធម្មជាតិ







- ការធ្វើស្រូវប្រពលវប្បកម្មតាមគោលការណ៍ធម្មជាតិ
- របៀបផ្សំទឹកមេជីធម្មជាតិ
- បទពិសោធន៍ធ្វើទឹកខ្មេះទឹកត្នោតជូរ

## គណៈកម្មការនិពន្ធ

បណ្ឌិត យ៉ង សាំងកុមារ
លោក យឹម សុផាណ្ណា
អ្នកស្រី ពាន សុខា
លោក ឡាង សេងហ៊ាង

## រួមចំណែកអត្ថបទលេខនេះ

បណ្ឌិត យ៉ង សាំងកុមារ
អ្នកស្រី ពាន សុខា
កញ្ញា ម៉ៅ តួចភក្ត្រា
លោក រាជ សុភាព
លោក គា គីមសាន
លោក អ៊ី ណារ៉ុន
លោក ឈុន វណ្ណឌី
លោក ប៊ុន ពេញភ័ក្ត្រ
លោក សាន ប៊ុនធឿន
លោក ផេង គា
លោក យី គីមថាន
លោក ហែម បូទុំ
លោក យ៉ង សាមី

## បោះពុម្ព និងចែកផ្សាយ

អ្នកស្រី ពាន សុខា
អ្នកស្រី គង់ លីនដា
កញ្ញា ព្រំ សោភ័ណ្ឌ
កញ្ញា ប៉ែន ចន្ទី
កញ្ញា ទុយ សុមាលី
លោក ហែម បូទុំ

បោះពុម្ពដោយ

**រោងពុម្ពផ្ទះយ៉ាមាស**

ចំនួន ៨០០០ ច្បាប់

# មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក/CEDAC)

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា **ជាអង្គការមិនមែន**រដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៍បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ ។ "សេដាក" ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍន៍សង្គមកម្ពុជាមួយប្រកបដោយចីរភាព និងសមធម៌ ដែលប្រជាកសិករ និងអ្នកបរិភោគមានជីវិតរស់នៅប្រកបដោយភាពសប្បាយរីករាយ ។

សេដាក បានចាប់ដៃជាមួយកសិករ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីផ្តួចផ្តើមគំនិត អនុវត្ត និងគាំទ្រដល់គំរោង ឬ សកម្មភាពដែលចូលរួមចំណែកដល់អធិបតេយ្យភាពស្បៀង និងការបង្កើននូវគុណភាពនៃជីវិតរបស់ប្រជាកសិករ និងអ្នកបរិភោគ ដោយជាមួយគ្នានោះរក្សា និងបង្កើននូវគុណភាពនៃធនធាន-ធម្មជាតិ និងការសហការគ្នាក្នុងសង្គម ។

## កម្មវិធីបោះពុម្ពផ្សាយព្រឹត្តិបត្រកសិករ

ព្រឹត្តិបត្រកសិករ ត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ខែដោយមជ្ឈមណ្ឌលយើង ចាប់តាំងពីខែមករា ឆ្នាំ ១៩៩៩ ក្នុងគោលបំណង :

- ចងក្រង និងកត់ត្រាទុកនូវរាល់ចំណេះដឹង និងបទពិសោធន៍ល្អៗ របស់កសិករពីតំបន់មួយ ផ្សព្វផ្សាយដល់កសិករនៅតំបន់ផ្សេងៗ ទៀត ដើម្បីធ្វើការសាកល្បងតាម
- ផ្តល់នូវបទពិសោធន៍ និងពត៌មានថ្មីៗ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្មដល់កសិករ និងអ្នកបច្ចេកទេសផ្សព្វផ្សាយកសិកម្ម សំដៅពង្រីកចំណេះដឹងឱ្យបានទូលំទូលាយ
- ជាវេទិកាសំរាប់ពិភាក្សាលើបញ្ហាទាក់ទងទៅនឹងការអភិវឌ្ឍន៍កសិកម្មជាលក្ខណៈគ្រួសារ នៅកម្ពុជា ។

# មាតិកា


∴ **បរិយាយលេខនេះ**

∴ **ផលិតកម្មដំណាំ**

- បទពិសោធន៍ធ្វើស្រែប្រពលវប្បកម្មតាមគោលការណ៍ធម្មជាតិ របស់កសិករ **ម៉ៅ ឆាស**...............................................៣
- បទពិសោធន៍ដាំត្រសក់ទ្រើង...............................................៥
- បទពិសោធន៍ដាំថ្លីដូង...............................................៦
- បទពិសោធន៍ផ្សាំក្រូចឆ្មារ...............................................៨
- បទពិសោធន៍ប្រើប្រាស់ថ្នាំផ្សំពីរុក្ខជាតិ...............................................៩
- របៀបផ្សំទឹកមេជីធម្មជាតិ...............................................១០

∴ **ផលិតកម្ម និងបសុព្យាបាល**

- បទពិសោធន៍ចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ...............................................១២

∴ **វារីវប្បកម្ម និងនេសាទ**

- បទពិសោធន៍ទាក់ទាញត្រីធម្មជាតិ...............................................១៦

∴ **ការប្រមូលទុកដាក់ និងកែច្នៃផលិតផល**

- បទពិសោធន៍ធ្វើទឹកខ្មេះទឹកត្នោតជូរ...............................................១៧

∴ **កសិដ្ឋានពហុប្រយោជន៍**

- បទពិសោធន៍រៀបចំកសិដ្ឋានពហុប្រយោជន៍...............................................១៨

∴ **ទំព័រសុខភាព**

- ថ្នាំពុល និងបញ្ហាសុខភាព...............................................២០
- វិធីព្យាបាលមុនតាមបែបធម្មជាតិ...............................................២១

∴ **ពីនេះពីនោះ**

- កំណាព្យ : បញ្ហាថ្នាំពុល...............................................២២
- ពិធីសម្ពោធមជ្ឈមណ្ឌលធនធានឯកសារ កសិករនៅស្រុកត្រាំកក់ ខេត្តតាកែវ...............................................២៤
- តំលៃផលិតផលកសិកម្មលើទីផ្សារក្រុងភ្នំពេញ...............................................២៥




ចំការត្រសក់ទ្រើងរបស់អ្នកមីង **កង ហ៊ុម**
រូបភាព : អ៊ិ ណារ៉ុន ( សេដាក )



របៀបផ្សាំក្រូចឆ្មារ
រូបភាព : អ៊ុំ មុន្នីធីតា ( សេដាក )



ទិដ្ឋភាពកសិដ្ឋានពហុប្រយោជន៍
រូបភាព : អ៊ិ ណារ៉ុន ( សេដាក )

## បរិយាយលេខនេះ

# ទស្សនាវដ្តីកសិករ និងការអភិវឌ្ឍន៍កសិកម្មជាលក្ខណៈគ្រួសារ

អង្គការសេដាក បានចាប់កំណើតនៅថ្ងៃទី ០១ ខែសីហា ឆ្នាំ ១៩៩៧។ ដូចនេះ មកដល់ខែសីហា ឆ្នាំ ២០០៤ យើងមានអាយុ ៧ ឆ្នាំហើយ។ ក្នុងរយៈពេលកន្លងមកនេះ យើងបានបំពេញការងារជាច្រើនដែលផ្តោតទៅលើការលើកតំកើងសុខមាលភាពគ្រួសារកសិករ និងអ្នកបរិភោគ តាមរយៈការជំរុញកសិកម្មតាមគោលការណ៍ធម្មជាតិ និងការពង្រឹងសមត្ថភាពសហគមន៍កសិករ។

ទស្សនាវដ្តីកសិករ ជាឧបករណ៍មួយសំខាន់ក្នុងការកត់ត្រា និងផ្សព្វផ្សាយនូវបទពិសោធន៍ល្អៗ គំនិតច្នៃប្រឌិតថ្មីៗ របស់កសិករ។ នៅពេលចាប់ផ្តើមដំបូង យើងមានការបោះពុម្ពផ្សាយចំនួនតែ ៥០០ ច្បាប់ តែមកដល់ពេលនេះបរិមាណដែលបោះពុម្ពផ្សាយមានការកើនឡើងដល់ចំនួន ៨០០០ ច្បាប់ ក្នុងមួយលេខ។ នេះឆ្លុះបញ្ចាំងអំពីតំរូវការនៃទស្សនាវដ្តីកសិករ និងការរីកដុះដាលនៃចំនួនកសិករដែលបានសហការជាមួយអង្គការសេដាក និង អង្គការ ឬស្ថាប័នជាដៃគូ។




កន្លងមក យើងព្យាយាមស្រាវជ្រាវរកនូវបទពិសោធន៍ប្លែកៗតែយើងក៏ចុះផ្សាយនូវករណីសិក្សាជាច្រើនមួយចំនួនជាពិសេស ស្រូវ ការចិញ្ចឹមមាន់ និងកសិដ្ឋានពហុប្រយោជន៍។ ការចុះផ្សាយនូវករណីសិក្សាលើប្រធានបទនេះជាស៊េរី ដោយស្រង់បទពិសោធន៍ពីកសិករផ្សេងៗ លើប្រធានបទដដែល គឺសំដៅចង់បង្ហាញកសិករឱ្យឃើញថាពិតជាមានអ្នកដែលអនុវត្តនូវគំនិតថ្មីទាំងនេះបានដោយជោគជ័យពិតប្រាកដមែន ហើយម្នាក់ៗមានភាពច្នៃប្រឌិតផ្សេងៗគ្នា។ ជាពិសេសជាងនេះទៀត យើងចង់បង្ហាញឱ្យឃើញថាតាមពិតសក្តានុពលក្នុងការបង្កើនផលិតផលកសិកម្ម និងប្រាក់ចំណូលមានកំរិតខ្ពស់ តែសំខាន់គឺយើងត្រូវចេះផ្លាស់ប្តូរនូវទំលាប់ និងមានភាពច្នៃប្រឌិតក្នុងការអនុវត្តន៍នូវបច្ចេកទេសសាមញ្ញៗ ក៏ដូចជាបង្កើនភាពយកចិត្តទុកដាក់ ឧស្សាហ៍ព្យាយាមបន្ថែមលើការងារ។

ជូសមុខឱ្យអង្គការសេដាក និងក្រុមអ្នកនិពន្ធ យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកចូលរួមចំណែកជាអត្ថបទដល់ទស្សនាវដ្តីកសិករទាំងអស់ និងជាពិសេសដល់កសិករទាំងអស់ដែលមានសណ្តានចិត្តល្អក្នុងការចែករំលែកនូវបទពិសោធន៍ និងគំនិតប្លែកៗផ្ទាល់ខ្លួនដល់កសិករដទៃ។ សូមឱ្យវប្បធម៌នៃការចែករំលែកនេះមានបន្តជាប់ជានិច្ច មិនត្រឹមតែតាមរយៈទស្សនាវដ្តីកសិករទេ តែតាមរយៈកសិករទៅកសិករផ្ទាល់តែម្តង។

**បណ្ឌិត យ៉ង សាំងកុមារ**

# បទពិសោធន៍ធ្វើស្រែប្រពលវប្បកម្មតាមគោលការណ៍ធម្មជាតិរបស់កសិករ ម៉ៅ មាស

កសិករ **ម៉ៅ មាស** អាយុ ៣១ ឆ្នាំ រស់នៅភូមិកំពោត ឃុំត្រប់ ស្រុកបាធាយ ខេត្តកំពង់ចាម។ គាត់មានសមាជិកគ្រួសារ ៦ នាក់។

នៅចុងឆ្នាំ ២០០២ គាត់បានចូលសហការជាមួយអង្គការអ្នកអភិវឌ្ឍន៍សហគមន៍ (NAS) ហើយបានទទួលការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មតាមគោលការណ៍ធម្មជាតិ និងបានទៅធ្វើទស្សនកិច្ចរៀនសូត្រពីកសិករសហការជាមួយអង្គការសេដាក នៅស្រុកត្រាំកក់ ខេត្តតាកែវ។ ទន្ទឹមនឹងនេះ គាត់បានអានទស្សនាវដ្តីកសិករបន្ថែម ដែលធ្វើអោយគាត់មានការចាប់អារម្មណ៍ និងជឿជាក់យ៉ាងខ្លាំងលើបច្ចេកទេសនេះ។

នៅដើមឆ្នាំ ២០០៣ គាត់សំរេចចិត្តសាកល្បងធ្វើស្រែ ប.វ.ស លើផ្ទៃដីចំនួន ៦ អារ ទាំងអស់របស់គាត់ ហើយបានទទួលទិន្នផល ៣៣៥ គីឡូក្រាម (ស្មើនឹង ៥.៥៨ តោន ក្នុង ១ ហិកតា) ដោយប្រើពូជអស់ចំនួនតែ ១ គីឡូក្រាម ប៉ុណ្ណោះ។ បើធ្វើស្រែតាមទំលាប់ នៅលើផ្ទៃដីដដែលនេះ គាត់ប្រើពូជអស់ ៨៤ គីឡូក្រាម ហើយទទួលផលបានតែ ១១៣ គីឡូក្រាម (ស្មើនឹង ១.៨៨ តោន ក្នុងមួយហិកតា) ប៉ុណ្ណោះ។ បច្ចេកទេស ប.វ.ស ដែលគាត់អនុវត្តមានដូចខាងក្រោម :

### ១. ការរៀបចំពូជសាប

មុនសាប គាត់បានយកគ្រាប់ពូជស្រូវ (ពូជអ៊ីអ៊ែរ ៦៦) ទៅត្រាំលាងជាមួយទឹកអំបិលក្តៅឧណ្ហៗ ដោយស្រង់យកគ្រាប់អណ្តែតចេញ ហើយគ្រាប់ល្អដែលនៅសល់ ច្រកបាវដាក់ត្រាំទឹកធម្មតាចំនួន ២ យប់ រួចទើបយកទៅសាប។

### ២. ការរៀបចំថ្នាលសំណាប

ចំពោះថ្នាលសំណាបវិញ គាត់បានលើកជារងដូចជារងបន្លែ ហើយដាក់ជីកំប៉ុស្ត និងរោយផេះអង្កាមពីលើឱ្យស្តើងៗ ទើបយកគ្រាប់ទៅសាប។

### ៣. ការរៀបចំដីសំរាប់ស្ទូង

នៅលើដីស្រែសំរាប់ស្ទូង គាត់បានយកកំទេចសំរាមស្លឹកឈើ ជីកំប៉ុស្ត រាយលើដី រួចបញ្ចូលទឹកទៅក្នុងស្រែឱ្យភក់ៗ ទើបភ្ជួរត្រឡប់។ រយៈពេល ៤ ទៅ ៥ ថ្ងៃបន្ទាប់ គាត់ចាប់ភ្ជួរ ១ សាទៀត ហើយរាស់ឱ្យស្មើដើម្បីត្រៀមស្ទូង។



កសិករ ម៉ៅ មាស កំពុងស្ទូងស្រូវ ប.វ.ស

### ៤. ការស្ទូង

គាត់ដកសំណាបអាយុ ១១ ថ្ងៃ យកទៅស្ទូង។ គាត់ដកសំណាបថ្នមៗ មិនឱ្យដាច់ឫសដាក់ក្នុងចានដែក។ គាត់ដកសំណាបភ្លាម យកទៅស្ទូងភ្លាម ដោយស្ទូងផ្តិតរាក់ៗ ស្ទូង ១ ដើមក្នុង ១ គុម្ព មានទុកចន្លោះពីគុម្ព ១ ទៅ គុម្ព ១ ប្រវែង ២.៥ តឹក និងស្ទូងជាជួរ ដូចដំណាំពោត។

### ៥. ការថែទាំ

ក្រោយពីស្ទូងហើយបាន ១០ ថ្ងៃ គាត់ចុះដកស្មៅ បំផុសដី និងថែមជីកំប៉ុស្ត ដើម្បីជំនួយដល់ការបែកគុម្ព។ ១៥ ថ្ងៃបន្ទាប់ គាត់ចុះដកស្មៅ លើកទី ២ ការធ្វើស្មៅប្រព្រឹត្តទៅ ៣-៤ ដងរហូតដល់ប្រមូលផល។

### ៦. សន្ទុះបែកគុម្ព និងទិន្នផល



ទិដ្ឋភាពស្រូវ ប.វ.ស បែកគុម្ព

ក្រោយពីការថែទាំបំប៉នដី គាត់សង្កេតឃើញថា ស្រូវមានដើមធំរឹងមាំ។ ស្រូវ ១ ដើម បែកបានតិចបំផុតចំនួន ២០ ដើម ខ្ពស់បំផុត ៥០ ដើម និងមធ្យម ៣៨ ដើម ក្នុងមួយគុម្ព។ ហើយទិន្នផលបើគិតជាហិកតាបាន ៥.៥៨តោន ក្នុង ១ ហិកតា។

### ៧. ចំណាប់អារម្មណ៍របស់កសិករ ម៉ៅ មាស ក្រោយការសាកល្បង :

ក្រោយពីសាកល្បងហើយ គាត់មានភាពជឿជាក់កាន់តែខ្លាំង ព្រោះឃើញបានផលចំណេញច្រើនដូចជា ពូជប្រើអស់តិច ជីគីមីមិនបានទិញប្រើ ដីមានជីជាតិល្អជាងមុន ហើយទិន្នផលស្រូវបានកើនជាងមុន ៣ ដង។

សំរាប់ទៅថ្ងៃមុខ គាត់នឹងបន្តអនុវត្តបច្ចេកទេស ប.វ.ស នេះទៀត ហើយកែប្រែចំនុចមួយចំនួនដូចជា :

- ខំសន្សំ និងប្រើជីកំប៉ុស្តឱ្យបានច្រើនជាងមុន
- ជ្រើសរើសយកតែសំណាបថ្លោសៗ យកទៅស្ទូង។

**សាន ប៊ុនធឿន និង ជ័យ ពិច**



# បទពិសោធន៍ដាំត្រសក់ទ្រើង

អ្នកមីង **កង ហ៊ឹម** ជាកសិកររស់នៅភូមិថ្មចាប ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ គាត់មានបទពិសោធន៍ដាំត្រសក់ទ្រើងបានផលច្រើន ដោយមិនប្រើថ្នាំពុល និងជីគីមី។ បទពិសោធន៍នេះ គាត់ចេះពីលោកពូ **ឆុក ឈឹម** ដែលជាគ្រូកសិករសហការជាមួយអង្គការសេដាក។ បទពិសោធន៍ដាំត្រសក់របស់អ្នកមីងមានបង្ហាញជូនដូចខាងក្រោម :

## ១. របៀបរៀបចំពូជសំរាប់ដាំ

មុនដាំ គាត់បានយកគ្រាប់ពូជទៅត្រាំរយៈពេល ១ ថ្ងៃ បន្ទាប់មកស្រង់វាផ្អាប់ទុក ហើយប្រស់ទឹកឱ្យសើមជាប់ជានិច្ច ១ ថ្ងៃ ២ ដង។ នៅពេលគ្រាប់បែកមាត់ចាបចេញពន្លកស១ ទើបគាត់យកគ្រាប់ទៅដាំ។

## ២. របៀបធ្វើដីដាំ

គាត់ភ្ជួរដីហាលចំនួន ៧ ថ្ងៃ បន្ទាប់មកលើកជារងដាំ។ រងមាន ២ ប្រភេទ នៅរដូវវស្សាគាត់លើករងខ្ពស់ជាងរាងខ្នងអណ្តើក នៅរដូវប្រាំងលើករងទាបដោយមានរាងដក់កណ្តាល។ រងមានទទឹង ១.៥ ម៉ែត្រ និងបណ្តោយទៅតាមស្ថានភាពដី។ នៅលើរង គាត់បានកប់ជីធម្មជាតិមានលាមកសត្វពុកផុយ និងកាកសំណល់រុក្ខជាតិ ( ស្លឹកឈើ សំរាម....) ។

## ៣. ការដាំ

គាត់ដាំនៅលើផ្ទៃដី ចំនួន ៦ អារ ដោយជីករណ្តៅនៅលើរងចន្លោះពីរណ្តៅមួយ ទៅមួយ ១ តឹក។ ក្នុងមួយរណ្តៅគាត់ដាំ ១ គ្រាប់ ដោយកប់ជំរៅ ១ តឹក។

## ៤. ការថែទាំ

គាត់ឧស្សាហ៍ចុះបោចស្មៅ ជ្រោយដី និងប្រើជីកំប៉ុស្តទឹកបន្ថែម។ ជីកំប៉ុស្តទឹក គាត់ផ្សំពីស្លឹកគ្រៃ ស្លឹកស្តៅ អាចម៍គោស្រស់ ទន្រ្ទាងខែត្រ ច្របល់លាយចូលគ្នាត្រាំជាមួយទឹកនោមគោ ទុករយៈពេល ២0 ថ្ងៃ ទើបយកមកប្រើ។ នៅពេលប្រើ គាត់យកទឹកជី ១ លីត្រ លាយជាមួយទឹក ១0 លីត្រ ស្រោចលើដំណាំ ក្នុងមួយថ្ងៃ ២ ដង។



អ្នកមីង កង ហ៊ឹម កំពុងត្រួតពិនិត្យថែទាំត្រសក់

## ៥. ការប្រមូលផល

ក្រោយពីដាំបានរយៈពេល ៤៥ ថ្ងៃ គាត់បេះប្រមូលផល។ ក្រៅពីទុកបរិភោគ និងចែកអ្នកជិតខាង គាត់អាចប្រមូលផលបាន ៣00 គីឡូក្រាម សំរាប់លក់ដែលបានទឹកប្រាក់ចំនួន ១៦៥ 000 រៀល ទៀត។

៦. ចំណាប់អារម្មណ៍ក្រោយពេលដាំ

អ្នកមីងបានឱ្យដឹងថាពីមុនគាត់ដាំប្រើជីគីមី និងថ្នាំពុល បច្ចុប្បន្ននេះ គាត់បានរៀនសូត្រពីកសិករ **ឆ៊ុក ឈឹម** ឃើញថា មានភាពខុសគ្នាច្រើនណាស់ចំពោះការដាំតាមគីមី និងធម្មជាតិ ទាំងការចំណាយ និងគុណភាពនៃត្រសក់។ តាមការប្រៀបធៀបពី



គុណភាពនៃត្រសក់ឃើញថា ដាំដោយប្រើជីគីមី សំបកត្រសក់គគ្រាត ក្រាស់ ផ្លែមិនសូវថ្លោស រសជាតិមិនសូវផ្អែម។ រីឯការដាំតាមគោលការណ៍ធម្មជាតិ ផ្លែត្រសក់មានសំបករលីង ស្ដើង ផ្លែថ្លោសល្អ រសជាតិផ្អែម ហើយផ្លែបានច្រើន ការប្រមូលផលបានរៀងរាល់ថ្ងៃ។ ការដាំដោយប្រើជីគីមីយើងអាចប្រមូលផលមួយថ្ងៃខានមួយថ្ងៃ។ ម្យ៉ាងទៀតគាត់សង្កេតឃើញថា ការប្រើជីទឹក មិនត្រឹមតែជួយផ្ដល់ជីជាតិឱ្យត្រសក់ទេ ថែមទាំងជួយបណ្ដេញសត្វល្អិតបំផ្លាញត្រសក់ទៀតផង។ គាត់បានបន្តទៀតថា ទៅថ្ងៃមុខគាត់នឹងផ្សព្វផ្សាយ ប្រមូលអ្នកភូមិរបស់គាត់ឱ្យដាំបន្លែតាមគោលការណ៍ធម្មជាតិវិញ ព្រោះបានចំណេញថវិកាច្រើន និងមិនខូចសុខភាពដល់អ្នកដាំ និងអ្នកបរិភោគ។ ជាទីបញ្ចប់ គាត់ក៏បានថ្លែងអំណរគុណដល់កសិករ **ឆ៊ុក ឈឹម** ដែលបានផ្ដល់បច្ចេកទេសនេះដល់គាត់។

**ស៊ុំ ណារ៉ុន**

---

## បទពិសោធន៍ដាំថ្នីដូង

កសិករ **ឆែម ឆើត** មានអាយុ ៣១ ឆ្នាំ ជាកសិករបង្គោលសហការជាមួយអង្គការសេដាក រស់នៅភូមិកណ្ដាល ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ក្រោយពីបានទទួលការបណ្ដុះបណ្ដាលពីអង្គការសេដាក មក គាត់បានរៀបចំកសិដ្ឋានពហុប្រយោជន៍ដែលមានចិញ្ចឹមត្រី មាន់ ទា និងដាំដំណាំចំរុះជាច្រើនមុខ។ ក្នុងនោះ គាត់មានបទពិសោធន៍ដាំដំណាំថ្នីបានយ៉ាងល្អ។ បទពិសោធន៍នេះបង្ហាញជូនដូចខាងក្រោម :

**១. ការរៀបចំថ្នាលបណ្ដុះ និងការបណ្ដុះ**

មុននឹងដាំគាត់សាបគ្រាប់ជាមុន។ នៅលើថ្នាលសាបគាត់បានរៀបចំដី ជ្រុំដាក់ជីកំប៉ុស្តឱ្យបានច្រើនដើម្បីឱ្យកូនថ្នីដុះបានល្អ និងងាយស្រួលដកយកទៅដាំ។ បន្ទាប់ពីរៀបចំថ្នាលសាបហើយ គាត់យកគ្រាប់ថ្នីទៅសាបលើរងឱ្យស្មើដៃ រួចស្រោចទឹកផ្សើមតិចៗ ពីលើ។ ការថែទាំបន្តរហូតដល់កូនថ្នីបានអាយុ ១៥ ថ្ងៃ ទើបដកយកទៅស្ទូងនៅលើរង។ ក្នុងរយៈពេលបណ្ដុះនេះ គាត់បានស្រោចជីកំប៉ុស្តទឹក ២ ដង ដើម្បីជំនួយដល់ការដុះលូតលាស់។

## ២. ការរៀបចំរងសំរាប់ដាំ

ក្នុងការរៀបចំរងនេះ គាត់កាប់ដីហាលចោលរយៈពេល ៣ ថ្ងៃ ដោយយកស្រទាប់ដីលើដាក់ខាងក្រោម និងស្រទាប់ក្រោមដាក់ខាងលើ។ រយៈពេល ៣ ថ្ងៃ បន្តមកទៀត គាត់កាប់ត្រឡប់ដូចមុនម្តងទៀត។ លើកទី ៣ កាប់ច្របល់លាយជាមួយជីកំប៉ុស្ត ផ្ទាប់ទុក ដោយស្រោចទឹកនៅលើរងឱ្យសើម ហើយយកដីខ្សាច់បាចគ្របពីលើស្តើងៗ ទុករយៈពេល ១០ ថ្ងៃ ទើបដកយកកូនផ្ទីមកស្ទូង។

## ៣. ការស្ទូងកូនផ្ទី

មុនស្ទូងកូន គាត់ជ្រុំច្របល់ដីលើរងឱ្យត្រសុសល្អ ទើបស្ទូងកូនផ្ទី។ ការស្ទូងកូនធ្វើនៅពេលល្ងាចត្រជាក់។ នៅលើរងគាត់ស្ទូង ៣ ជួរ ដោយចន្លោះពីដើមមួយ ទៅមួយ ១ តឹក។ ស្ទូងហើយគាត់ក្រាលចំបើងពីលើរួចស្រោចទឹកឱ្យជោគ។

## ៤. ការថែទាំ

ក្នុងការថែទាំ គាត់ស្រោចទឹក ១ ថ្ងៃ ២ ដង (ព្រឹក និងល្ងាច)។ ក្នុងកំឡុងពេលដែលផ្ទីកំពុងលូតលាស់ មានសត្វល្អិតខ្លះបំផ្លាញ ដូចជា ទៀកគូ ដង្កូវផ្សេងៗគាត់មិនស្គាល់ និងកណ្តូប មេអំបៅ គាត់ប្រើថ្នាំផ្សំពីរុក្ខជាតិដែលមានធាតុផ្សំដូចខាងក្រោម :

- ក្តាមចំនួន ២០-៣០ ក្បាល
- ថ្នាំជក់កន្លះខាំ
- ទឹកចំនួន ១០ លីត្រ
- សំបកស្តៅ និងស្លឹកស្តៅចំនួន ៣ គីឡូក្រាម

ថ្នាំត្រូវទុករយៈពេល ៧ ថ្ងៃ ទើបយកទៅប្រើ។ នៅពេលប្រើ គាត់លាយទឹកថ្នាំ ១ កំប៉ុង ជាមួយទឹកធម្មតា ១០លីត្រ។ គាត់ធ្វើការស្រោចស្រពទឹកថ្នាំរយៈពេល ៣ ថ្ងៃ ម្តង។ គាត់បានបញ្ជាក់ថា គេអាចប្រើបានលើដំណាំគ្រប់ប្រភេទ។

## ៥. ការប្រមូលផល :

ក្រោយពីស្ទូងកូនបានរយៈពេល ១៦ ថ្ងៃ គាត់អាចកាត់បរិភោគ និងលក់បាន។ គាត់ប្រមូលផលដោយកាត់ មិនដកទាំងឫសទេ។ ក្រោយពីកាត់ ១ លើកៗ គាត់ដាក់ជីកំប៉ុស្តបំប៉នបន្ថែម និងស្រោចទឹកថ្នាំការពារសត្វល្អិត និងជំនួយការដុះលូតលាស់។ គាត់កាត់ប្រមូលផលបានចំនួន ៤ លើកទើបដកចោលដាំដំណាំថ្មី។ ឯលទ្ធផលវិញ ក្រៅពីការបរិភោគក្នុងគ្រួសារ គាត់លក់បានប្រាក់ចំនួន ៩២០០០រៀល (៤ លើក)។ នៅមានដំណាំផ្សេងៗ ទៀតដែលគាត់បេះលក់ពីក្នុងកសិដ្ឋានរបស់គាត់។

ផេង តា

# បទពិសោធន៍ផ្សាំក្រូចឆ្មារ

កសិករ **នី នួន** រស់នៅភូមិធ្នង់ ឃុំស្តៅកោង ស្រុកបាភ្នំ ខេត្តព្រៃវែង គាត់មានបទពិសោធន៍ផ្សាំក្រូចឆ្មារបានទទួលផលល្អ។ បទពិសោធន៍នេះ គាត់បានច្នៃប្រឌិតដោយខ្លួនឯង។

## ១. ការជ្រើសរើសមែកសំរាប់ផ្សាំ

ដើម្បីឱ្យការផ្សាំប្រព្រឹត្តទៅបានល្អ ត្រូវជ្រើសរើសមែកផ្សាំមួយចំនួនដូចខាងក្រោម :

- ជ្រើសរើសយកមែកដែលមានអាយុពី ១ ឆ្នាំ ឡើងទៅ
- មែកដែលគ្មានជំងឺសត្វល្អិតបំផ្លាញ និងមានរាងរលូន (មែកបំពង់)



របៀបផ្សាំក្រូចឆ្មារ

## ២. របៀបផ្សាំ

- យកកូនកាំបិតមុតមកចៀរក្រឡឹងជុំវិញប្រវែង ២ តឹក
- បន្ទាប់ពីចៀរហើយត្រូវកោសឱ្យអស់ជាតិរំអិល
- ត្រៀមថង់ប្លាស្ទិក ក្រណាត់ ឬស្រកីដូងសំរាប់រុំ
- យកដីមានជីជាតិ ឬដីដំបូកផ្សើមដោយទឹកឱ្យដីមានសំណើម មករុំចងឱ្យជិតណែនទៅកន្លែងដែលផ្សាំ។

ដើម្បីឱ្យឫសលូតលាស់បានល្អ នៅរដូវប្រាំងត្រូវឧស្សាហ៍បន្តក់ទឹកលើមែកផ្សាំ។ ចំណែករដូវវស្សាមិនទាមទារការបន្តក់ទឹកទេ។

## ៣. របៀបកាត់មែកផ្សាំ

ក្រោយពីផ្សាំបានរយៈពេល ១៥ ទៅ ៣០ ថ្ងៃ គាត់កាត់មែកផ្សាំយកទៅដាំក្នុងចំការ។ នៅពេលដាំនៅក្នុងចំការ គាត់បានរៀបចំដីដែលមានជីជាតិលាយជីកំប៉ុស្ត (ដីពាក់កណ្តាល ជីកំប៉ុស្តពាក់កណ្តាល) ធ្វើការថែទាំស្រោចទឹកជារៀងរាល់ថ្ងៃរហូតដល់ក្រូចអាយុបាន ៣ ខែ គាត់បន្ថែមជីកំប៉ុស្តបំប៉ន និងថែទាំស្រោចទឹករហូតដល់ក្រូចធំមានផ្លែ។ រីឯការដាក់ជីបំប៉ន ១ ឆ្នាំ គាត់កាប់ដាក់ម្តង។

## ៤. ការប្រមូលផល

លោកពូបានឱ្យដឹងថា កាលពីមុនគាត់មិនទាន់ចេះបច្ចេកទេស គាត់ដាំដោយគ្រាប់។ បច្ចុប្បន្ននេះ គាត់ដាំដោយផ្សាំមែក ហើយសង្កេតឃើញថា ការដុះលូតលាស់នឹងឱ្យផលលឿនជាងការដាំដោយគ្រាប់។ ដំបូងគាត់មានក្រូចឆ្មារ ១០ ដើម ប៉ុន្តែបច្ចុប្បន្នគាត់ផ្សាំបានរហូត ៣០ ដើម។ ការបេះប្រមូលផលម្តងៗបាន ២៥ គីឡូក្រាម។ ក្រៅពីការបរិភោគក្នុងគ្រួសារ និងចែកអ្នកជិតខាងក្នុង ១ ឆ្នាំ ប្រមូលផលបាន ២-៣ ដង។ ការប្រមូលផលម្តងៗ លក់បាន ៦២៥០០ រៀល។ ក្រៅពីក្រូចឆ្មារ នៅកសិដ្ឋានរបស់គាត់ មានដំណាំចំរុះគ្រប់មុខ ដែលអាចបេះលក់បានគ្រប់មុខ និងរៀងរាល់ថ្ងៃ។

**ឌុំ ចុន្ទីធីតា**

# បទពិសោធន៍ប្រើប្រាស់ថ្នាំផ្សំពីរុក្ខជាតិកំចាត់សត្វបំផ្លាញដំណាំ

ꩰ☆ꩰ

លោកអ៊ុំ **ឌី សោធ** ជាកសិកររស់នៅភូមិត្រពាំងរាំង ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។ គាត់មានបទពិសោធន៍ក្នុងការផ្សំថ្នាំពីរុក្ខជាតិដើម្បីកំចាត់សត្វបំផ្លាញដំណាំ (ស្រូវ និងបន្លែ)។ បទពិសោធន៍នេះ គាត់បានចេះពីអង្គការសេដាកខ្លះ គួបផ្សំនឹងគំនិតច្នៃប្រឌិត និងចំណេះដឹងពីដូនតាគាត់មកផង។ បទពិសោធន៍ផ្សំថ្នាំនេះបង្ហាញជូនដូចខាងក្រោម :

## ១. ធាតុផ្សំ

ធាតុផ្សំសំខាន់ៗ ដែលគាត់ប្រើមានដូចជា :

- ស្លឹកស្តៅ
- បណ្តូលពេជ្រ
- កាកសំណល់ផ្ទះបាយ
- សំបកស្លែង
- មើមរំដេង
- ថ្នាំខ្លាំង
- ម្ទេសទុំ
- ទឹកនោមគោ



វល្លិ៍បណ្តូលពេជ្រ

ចំពោះស្លឹកស្តៅ បណ្តូលពេជ្រ និងសំបកស្លែង បរិមាណដែលប្រើគឺក្នុងកំរិតស្មើគ្នា។ ចំណែកទឹកនោមគោ គាត់ដាក់ត្រាំឱ្យលិចធាតុផ្សំខាងលើ។

## ២. របៀបផ្សំ និងប្រើប្រាស់

គាត់យកធាតុទាំងអស់ខាងលើ យកទៅចាក់ចូលក្នុងកូនពាង ឬក្រឡ គ្របឱ្យជិតរយៈពេល ១-២ ថ្ងៃ ធ្វើការកូរវាម្តង។ ការត្រាំនេះ មានរយៈពេល ១៥-៣០ ថ្ងៃ អាចយកទៅប្រើប្រាស់បាន។ រីឯរបៀបប្រើគឺនៅក្រោយពេលដំណាំមានអាយុមួយអាទិត្យ គាត់ចាប់ផ្តើមស្រោចថ្នាំនេះក្នុងបរិមាណ ១ កំប៉ុងទឹកដោះគោលាយជាមួយទឹក ១០ លីត្រ។ ជាទូទៅគាត់ប្រើថ្នាំនេះរយៈពេល ២-៣ ថ្ងៃ ម្តង។ គាត់បានបញ្ជាក់ថា ថ្នាំនេះត្រូវប្រើនៅមុនពេលមានការបំផ្លាញពីសត្វល្អិត បើសិនរង់ចាំដល់មានការបំផ្លាញខ្លាំង ទើបប្រើនោះថ្នាំពុំសូវមានប្រសិទ្ធិភាពទេ។

ការប្រើគឺធ្វើនៅពេលល្ងាច ត្រជាក់ ដើម្បីកុំឱ្យខូចគុណភាពរបស់ស្លឹកដំណាំ។ ចំពោះថ្នាំផ្សំនេះ ប្រើទៅមិនត្រឹមតែកំចាត់សត្វល្អិតបំផ្លាញដំណាំប៉ុណ្ណោះទេ (ស្រូវ និងបន្លែ) វាក៏ជាថ្នាំជំនួយក្នុងការលូតលាស់ផងដែរ។

ដូច្នេះ ដើម្បីជៀសវាងការចំណាយថវិកាច្រើន ក្នុងការចំណាយទៅលើថ្នាំពុលកសិកម្ម សូមបងប្អូនកសិករសាកល្បងនូវបទពិសោធន៍ដ៏សាមញ្ញខាងលើ។

# របៀបផ្សំទឹកមេជីធម្មជាតិ

កសិករ **ចាន់ សុធា** អាយុ ៣២ ឆ្នាំ រស់នៅភូមិទីប៉ាត់ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ គាត់មានបទពិសោធន៍ធ្វើទឹកមេជីស្រោចលើដំណាំដុះលូតលាស់បានល្អ។ បទពិសោធន៍នេះ គាត់ចេះពីកសិករថៃ ដែលអង្គការសេដាក បាននាំទៅធ្វើទស្សនកិច្ចសិក្សាកាលពីឆ្នាំមុន (២០០៣) គួបផ្សំនឹងគំនិតច្នៃប្រឌិតរបស់គាត់ផង។ បទពិសោធន៍ធ្វើមេជីរបស់គាត់បង្ហាញជូនដូចខាងក្រោម :

### ១. ធាតុផ្សំ និងរបៀបផ្សំ

យកត្រួយអង្កាញ់ ៣ ភាគ លាយចូលគ្នាជាមួយស្ករត្នោតមួយភាគ (ស្ករត្នោតក្រាមធម្មតា ឬទឹកស្កររងូក៏បាន) ដាក់ត្រាំនៅក្នុងធុងមួយដែលមានគ្របបិទជិត។ ១ថ្ងៃ យើងបង្អើបគ្របម្តង (បើកមួយភ្លែត) រួចបិទទៅវិញដើម្បីឱ្យមានខ្យល់ចេញចូល ដែលជួយឱ្យជីឆាប់កាច់។ យើងធ្វើរបៀបនេះរហូតដល់រយៈពេល ១៥ ថ្ងៃ ឡើងទៅគឺនៅពេលដែលយើងពិនិត្យឃើញផ្សិតសៗអណ្តែតនៅលើទឹក ហើយទឹកជីមានពណ៌ដូចទឹកតែ បើយើងលិទ្ធបន្តិចទៅវាមានរសជាតិជូរភ្លាវនោះយើងអាចយកទៅប្រើបាន។



ស្លឹកអង្កាញ់

### ២. របៀបប្រើ

គាត់ប្រើស្រោចនៅលើបន្លែ ជាពិសេស បន្លែស្លឹក ដូចជា ត្រកួន ស្ពៃ ផ្ទី ។ល។ ក្នុងបរិមាណ ១ ស្លាបព្រា ទឹកមេជីលាយជាមួយទឹក ១០ លីត្រ ស្រោចរយៈពេល ២-៣ ថ្ងៃម្តង។ ក្រោយពីស្រោចទឹកជីរួច ១៥ នាទី ត្រូវស្រោចទឹកធម្មតាលាងតាមក្រោយ។ ក្រោយពីស្រោចបានរយៈពេល ២ ទៅ ៣ ដង យើងឃើញការលូតលាស់មានសភាពប្រែប្រួលខ្លាំងដោយស្លឹក និងដើម ជាពិសេស ត្រកួនដុះទ្រុបទ្រុល និងមានពណ៌បៃតងខ្ចី គួរអោយចាប់អារម្មណ៍។

មិនត្រឹមតែស្រោចលើដំណាំប៉ុណ្ណោះទេ គាត់បានយកទឹកមេជីនេះស្រោចលើជីកំប៉ុស្ត ដើម្បីឱ្យវាឆាប់កាច់។ គាត់បានបញ្ជាក់ប្រាប់ទៀតថា តាមធម្មតាជីកំប៉ុស្តយើងផ្អាប់ទុករយៈពេល ៣ ខែ ទើបកាច់ និងអាចយកទៅប្រើបាន។ តែក្រោយពីប្រើទឹកមេជីនេះ ស្រោចពីលើរយៈពេលតែ ១ ខែ កំប៉ុស្តកាច់អាចយកទៅប្រើបាន។ ចំណែកឯបរិមាណដែលប្រើគឺ លាយដូចស្រោចលើដំណាំ (ទឹកមេជី ១ ស្លាបព្រា លាយទឹក ៣ លីត្រ) ។

### ៣. របៀបបំប៉នទឹកមេជី

**ទឹកមេជីដែល**យើងធ្វើបាន យើងអាចបំបែកធ្វើបន្តទៀត ដោយមិនចាំបាច់ធ្វើឡើងវិញជាថ្មីទេ។

**របៀបបំបែក**បង្ហាញដូចខាងក្រោម :

- យកទឹកមេជី ១ លីត្រ
- ស្ករត្នោត ១ គីឡូក្រាម (ទឹកស្កររងូក៏បាន)
- ទឹកធម្មតា ១០ លីត្រ

ធាតុផ្សំទាំង ៣ ដាក់លាយបញ្ចូលគ្នា ផ្អាប់ទុករយៈពេល ៣ ថ្ងៃ។ មួយថ្ងៃយើងបង្វើបគ្របម្តង (បង្វើបមួយភ្លែត) រួចបិទគ្របវិញធ្វើដូចខាងលើ។ ក្រោយពីធ្វើបានរយៈពេល ៣ ថ្ងៃ យើងអាចយកទៅប្រើបាន ដោយនៅពេលនោះយើងពិនិត្យឃើញមានផ្សិតស១អណ្តែតនៅខាងលើ និងមានជាតិជូរភ្លាវ។ ទឹកមេជីដែលបំបែកនេះមានប្រសិទ្ធិភាព និងបរិមាណនៃការប្រើប្រាស់ដូចមេជីដែលទើបធ្វើដំបូង។

ដោយផ្អែកលើជោគជ័យដែលទទួលបានកន្លងមក កសិករ ចាន់ សុធារ គ្រោងនឹងធ្វើការពិសោធន៍សាកល្បងបន្តទៀត។ គាត់យល់ឃើញថា កសិករដទៃទៀតសាកល្បងនូវវិធីសាស្ត្រ ដើម្បីដកពិសោធន៍ផ្ទាល់ខ្លួន។



**ទឹកមេជីដែលផ្សំពីស្លឹកអង្កាញ់ និងស្ករត្នោត**

**ពាន សុខា**

ផ្តល់ទឹក ឱ្យបានជាប្រចាំ។ នៅពេលកូនមាន់ញាស់បាន ១-២ គាត់ឧស្សាហ៍ទៅមើល និងយកសំបកពងនោះចេញពីសំបុក។ ដើម្បីដឹងថាពងមាន់ញាស់ ឬមិនញាស់ គាត់យកពងមាន់ទៅត្រាំទឹកមើលថាតើវាស្អុយ ឬក៏ល្អធម្មតា (ដាក់ពងមាន់ត្រាំក្នុងទឹកទៅបើវារង្គើមាន ន័យថាពងល្អ គ្រាន់តែមិនទាន់ញាស់)។ នៅពេលកូនមាន់ញាស់អស់ហើយគាត់លើកវាចេញពីសំបុក។ ជាទូទៅ មេមាន់ពងបានជាមធ្យមចំនួន ១២ ពង និងញាស់បានពី ១០-១១ ពង (៨៣ ភាគរយ ទៅ ៩០ ភាគរយ)។ ប៉ុន្តែក្នុងចំណោមពងទាំង ១០ ដែលញាស់ និងធំធាត់រហូតដល់បានលក់អាចងាប់ពី ១ ទៅ ៣។ ដូច្នេះ អត្រាមាន់រស់រហូតដល់បានលក់ប្រមាណពី ៧០ ទៅ ៩០ ភាគរយ នៃចំនួនពងដែលបានញាស់។

ការក្រុងកូនមាន់ក្រោយពេលញាស់



ការក្រុងកូនមាន់ក្រោយពេលញាស់

នៅពេលកូនមាន់ញាស់ភ្លាម គាត់មិនអោយមេវាបណ្តើរភ្លាមនោះទេ គឺក្រុងកូនមាន់ទាំងនោះរហូតបានរយៈពេលពី ៥ ទៅ ៧ ថ្ងៃសិន លុះត្រាតែកូនមាន់រឹងដើរឹងជើងហើយសិន ទើបព្រលែងឱ្យមេវាបណ្តើរ។ លោកពូបានបញ្ជាក់ប្រាប់ថា កូនមាន់ដែលទើបនឹងញាស់ហើយ ៤-៥ ថ្ងៃ មិនបាច់ឱ្យចំណីស៊ីក៏បានដែរ ពីព្រោះនៅក្នុងខ្លួនវានៅមានសារធាតុចិញ្ចឹមជាស្រេច លុះត្រាតែវាប្រើប្រាស់សារធាតុចិញ្ចឹមនោះអស់ ទើបយើងអោយចំណីវា។

ចំពោះកូនមាន់ លោកពូឱ្យចំណីចុងអង្ករ ឬអោយស៊ីចកតូចៗ ដោយមិនអោយកូនមាន់ស៊ីអង្ករ ស្រូវទេ ពីព្រោះវាធ្វើអោយកូនមាន់លេបមិនរួច និងក្អៀនអាចម៍ទៀតផង។ នៅពេលកូនមាន់អាយុបាន ១ ខែ គាត់បំបែកកូនមាន់ឈប់ឱ្យមេវាបណ្តើរ និងឱ្យមេវារកពងទៀត។ ពេលបំបែកពីមេវាគាត់ក្រាលសំដីស្រូវ កំទេចអង្កាមឱ្យកូនមាន់ដេក ដើម្បីបង្កើនភាពកក់ក្តៅដល់កូនមាន់។

### ៣. ការវិភាគចំណូលចំណាយលើការចិញ្ចឹមមាន់

#### ក. ការចំណាយ

សំភារៈមួយចំនួនសំរាប់សាងសង់របងធ្វើទ្រុងមាន់ គាត់អាចរកបាននៅក្នុងដីលំនៅដ្ឋានរបស់គាត់គឺ មិនបានទិញឬស្វ៊ីពីខាងក្រៅនោះទេ។ ដោយឡែក គាត់បានចំណាយលើសំភារៈមួយចំនួនដែលមិនអាចរកបានដូចជា ដែកគោល ស្បៃ ។ល។ សរុបអស់ទឹកប្រាក់ចំនួន ៨០០០ រៀល។

#### ខ. ចំណូល

ក្រៅពីការបរិភោគក្នុងគ្រួសារជាប្រចាំ មាន់នៅសល់ គាត់អាចលក់បានលុយខ្លះទៀតផង។

- នៅឆ្នាំ ២០០២ គាត់លក់បានទឹកប្រាក់សរុប ២២០ ០០០ រៀល
- នៅឆ្នាំ ២០០៣ គាត់លក់បានទឹកប្រាក់សរុប ១០០ ០០០ រៀល
- នៅឆ្នាំ ២០០៤ គាត់លក់បានទឹកប្រាក់សរុប ១១០ ០០០ រៀល

ដូចនេះក្នុងរយៈពេល ៣ ឆ្នាំ ក្រៅពីការបរិភោគក្នុងគ្រួសារ គាត់រកប្រាក់ចំណូលបាន ៧៥០ ០០០ រៀល ។ ក្រោយពីបានសាកល្បងបច្ចេកទេសនេះមកគាត់មានចំណាប់អារម្មណ៍ថា ការចិញ្ចឹមមាន់តាមបច្ចេកទេសនេះ មាន់មិនសូវងាប់ទេ ហើយបើប្រៀបធៀបទៅការចិញ្ចឹមតាមទំលាប់ក្នុង ១ឆ្នាំ មាន់ងាប់ ២-៣ ដង ។ ហើយការចិញ្ចឹមតាមលក្ខណៈធម្មតាមិនសូវល្អូតលាស់ទេ ចិញ្ចឹមរយៈពេល ៦ខែ មាន់មានទំងន់ ១.៥ គីឡូក្រាម ។ ចំណែកចិញ្ចឹមតាមបច្ចេកទេសរយៈពេលតែ ៤ ខែ មាន់មានទំងន់ ១.៥ គីឡូក្រាម ។ សរុបមក បច្ចេកទេសដែលលោកពូអនុវត្តបានល្អមានដូចជា :

- ធ្វើរបងព័ទ្ធទីធ្លាសំរាប់មាន់ដើររកចំណី
- ធ្វើទ្រុងសំរាប់អោយមាន់ដេក
- ដាក់ស្នូកទឹក ស្នូកចំណីសំរាប់មាន់ និងលាងសំអាតជាប្រចាំ
- ត្រាំសំបកស្ពៅ គរ ឱ្យមាន់ផឹកការពារជំងឺ
- ផ្តល់ចំណីចំរុះឱ្យមាន់មានដូចជា ស្រូវ ចុងអង្ករ កន្ទក់ ចក ត្រកួនឱ្យមាន់ស៊ី
- ឧស្សាហ៍ប្រែត្រឡប់ពងដើម្បីអោយពងមាន់ញាស់ស្រុះល្អ
- ធ្វើទ្រុងដាក់កូនមាន់ផ្សេងគ្នាពីទ្រុងដាក់មាន់ធំ
- ទំលាក់ព្រូនមួយអាទិត្យម្តង ដោយប្រើស្លាខ្ចី ផ្លែកន្ធំថេត និងស្លឹកបុកលាយធ្វើជាចំណីអោយស៊ី
- កំចាត់ស្រមើរដោយដាក់ស្លឹកស្ពៅ ស្លឹកប្រចាក់ ។ល។ ក្រាលនៅបាតសំបុក ។



ប្រពន្ធរបស់កសិករ ហុង ស៊ាន កំពុងផ្តល់ទឹកនិងផ្តល់ចំណីឱ្យមាន់

**ប៊ុន ពេញភ័ក្រ្ត**

# វារីវប្បកម្ម និងនេសាទ

## បទពិសោធន៍ទាក់ទាញត្រីធម្មជាតិរបស់កសិករ

កសិករ **ជា ទន** រស់នៅភូមិតាសូ ឃុំឧត្តមសូរិយា ស្រុកត្រាំកក់ ខេត្តតាកែវ។ គាត់មានមុខរបរធ្វើស្រែ ដាំដំណាំ និងធ្វើនំបញ្ចុកលក់។ គាត់បានចូលរួមសហការជាមួយអង្គការ សេដាក និងបានទទួលការបណ្តុះបណ្តាលលើបច្ចេកទេសទាក់ទាញត្រីធម្មជាតិ។ ក្រោយពីបានទទួលបច្ចេកទេសទាក់ទាញត្រីធម្មជាតិនេះមក គាត់មានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយបានយកបទពិសោធន៍នេះទៅសាកល្បង ដោយគួបផ្សំនឹងបទពិសោធន៍របស់គាត់ដែលមានពីមុនមកផង។ ក្រោយពីបានអនុវត្តបច្ចេកទេសថ្មីនេះ គាត់ទទួលបានផលត្រី ១២០ គីឡូក្រាម ដែលខុសពីមុនដែលគាត់ធ្វើតាមទំលាប់បានទទួលតែ ៧០ គីឡូក្រាមប៉ុណ្ណោះ។ ចំពោះបច្ចេកទេសដែលគាត់អនុវត្តបង្ហាញជូនដូចខាងក្រោម :



ទិដ្ឋភាពស្រះទីជ្រំត្រី

ក. ការរៀបចំស្រះ

- ជីកស្រះដែលមានទំហំ ២៣៤ ម៉ែត្រការ៉េ និងជំរៅ ១.៥ ម៉ែត្រ
- កាត់មែកឈើជុំវិញមាត់ស្រះ
- បើករង្វះទឹក ៤ ច្រក ដោយភ្ជាប់ពីប្រព័ន្ធប្រឡាយក្នុងស្រែមកចូលស្រះ
- ដាក់គល់ឈើបាតស្រះដូចជា មែក និងគល់អំពិលទឹក គល់ត្នោត (ទំហំសំរាប់ដាក់បាតស្រះ ៥ ម៉ែត្រការ៉េ)
- ដាំកំប្លោកអោយដុះរុំចុងឬស្សីធ្វើជាស៊ុំដោតកណ្តាលស្រះ (ទំហំជំរកលើផ្ទៃស្រះ ៦ ម៉ែត្រការ៉េ)

ខ. ការផ្តល់ចំណី

ចំណីដែលបានផ្តល់ឱ្យត្រីស៊ីមានកន្ទក់ កណ្ឌៀរ អង្រ្កង ដើមចេកហាន់បុកលាយកន្ទក់ និងសំណល់ក្រោយពីធ្វើនំបញ្ចុក។ គាត់ផ្តល់ចំណីអោយត្រីស៊ី ៤-៥ ថ្ងៃ ក្នុង ១ អាទិត្យ (១ ថ្ងៃ អោយស៊ី ០.៥-១ គីឡូក្រាម)។

គ. ការគ្រប់គ្រង និងថែទាំ

ដើម្បីឱ្យត្រីឆាប់ធំធាត់ និងមិនងាប់គាត់ត្រូវគ្រប់គ្រងថែទាំដូចខាងក្រោម :

- រក្សាកំប្លោកមិនឱ្យដុះលើសពីរង្វង់ស៊ុំដែលដោតនៅកណ្តាលស្រះ
- ស្រះរបស់គាត់មានម្លប់ស្វាយគ្របពីលើផ្ទៃស្រះប្រហែលជា ២០ ភាគរយ
- ការពារមនុស្សឆក់ និងបង់សំណាញ់
- ផ្តល់ចំណីរៀងរាល់អាទិត្យ
- រក្សាទឹកបានពេញ ១ ឆ្នាំ (មិនបូមផ្តាច់ពូជ)
- រក្សាត្រីមេពូជដែលចាំជំរក។



ការប្រមូលផលត្រី

ដើម្បីឱ្យបានផលត្រីច្រើនជាងនេះគួរកែលំអចំណុចមួយចំនួនដូចជា: រៀបចំស្រះ ស្តារភក់នៅបាតស្រះ បាចកំបោរសនៅបាតស្រះ ០.០៧ គីឡូក្រាម ក្នុង ១ ម៉ែត្រការ៉េ នៃផ្ទៃស្រះ (សំលាប់មេរោគ ថែទឹកឱ្យថ្លា.....) និងបង្កើតចំណីធម្មជាតិ ដូចជា ការដាក់លាមកសត្វគោ ឬក្របី ០.៤ ក្នុង ១ ម៉ែត្រការ៉េនៃផ្ទៃស្រះ និងទន្រ្ទានខែត្រ ០.៣ គីឡូក្រាម ក្នុង ១ ម៉ែត្រការ៉េនៃផ្ទៃស្រះនោះ ផលត្រីនឹងអាចកើនបានច្រើនជាងនេះទៅទៀត។

**រាជ សុភាព**

## បទពិសោធន៍ធ្វើទឹកខ្មេះទឹកត្នោតជូរ

ខេត្តតាកែវ ជាខេត្តដែលសំបូរដើមត្នោត។ ក្រៅពីរបរធ្វើស្រែ កសិករប្រកបរបរឡើងត្នោត។ ទឹកត្នោតដែលគាត់គាបបាន យកទៅរំងាស់ធ្វើជាស្ករត្នោតទុកបរិភោគ ឬសំរាប់លក់។ កសិករខ្លះគាត់លក់ទឹកត្នោតផ្អែម នៅពេលដែលលក់មិនអស់ គាត់បានកែច្នៃធ្វើជាទឹកខ្មេះ។ ជាក់ស្តែងអ្នកមីង **គុច សំអុន** ដែលជាកសិកររស់នៅភូមិចមពល ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ គាត់មានបទពិសោធន៍កែច្នៃទឹកត្នោតជូរធ្វើទឹកខ្មេះមានរសជាតិឆ្ងាញ់ ហើយទុកបានយូរ។ បទពិសោធន៍នេះ គាត់ចេះពីយាយក្មេករបស់គាត់។ នៅលេខនេះ ខ្ញុំសូមលើកយកបទពិសោធន៍ធ្វើទឹកខ្មេះរបស់គាត់ មកចែកជូនបងប្អូនកសិករទុកជាគំនិតសំរាប់កែច្នៃដូចខាងក្រោម :

១ <u>របៀបធ្វើ</u>



**អ្នកមីង គុច សំអុន ដែលបានកែច្នៃទឹកខ្មេះពីទឹកត្នោតជូរ**

ដើម្បីឱ្យទឹកខ្មេះទុកបានយូរ គាត់លាងខាប់ (ពាង) ឱ្យស្អាត រួចចាក់ទឹកត្នោតចូលទៅក្នុងខាប់ ដោយច្រោះយកកំទេចឈើ (សំបកពពាល) ចេញ។ ក្រោយពីចាក់ទឹកត្នោតចូលក្នុងខាប់ ហើយគាត់អាំងចេកទុំចំនួន ១០-១៥ ផ្លែ (ទឹកត្នោត ៣០ លីត្រ ដាក់ចេក ១០ ផ្លែ) ដាក់ត្រាំក្នុងទឹកត្នោតដើម្បីឱ្យឆាប់ឡើងមេជូរ។ យើងអាចយកដំឡូងជ្វាទៅដុតដាក់ត្រាំក្នុងទឹកត្នោតក៏បាន (ដំឡូងដុត ៧ ទៅ ១០ មើមធំៗ ត្រាំជាមួយទឹកត្នោត ៣០ លីត្រ) បន្ទាប់មកគ្របទុកហាលថ្ងៃរយៈពេល ១ អាទិត្យ ទើបបើកមើល បើឃើញជូរហើយមានដុះមេសៗ ធ្លាក់ចុះទៅក្រោម និងទឹក ខាងលើរងថ្លានោះយើងអាចយកទៅបរិភោគបាន។

អ្នកមីងបានបញ្ជាក់ទៀតថា ប្រសិនបើយកទឹកត្នោតផ្អែមទៅធ្វើក៏បានដែរតែយើងទុកក្នុងរយៈពេលយូរពី ១-១.៥ ខែ ទើបជូរអាចយកទៅបរិភោគបាន ហើយវាមានរសជាតិឆ្ងាញ់ជាងទឹកត្នោតជូរ។

ក្រោយពីបានកែច្នៃមក អ្នកមីងមានចំណាប់អារម្មណ៍ថា ទឹកខ្មេះនេះមានរសជាតិឆ្ងាញ់ ហើយទុកបានយូរ មិនប៉ះពាល់ដល់សុខភាពដូចទឹកខ្មេះជាតិគីមី ដែលគេលក់នៅទីផ្សារ។

ជាទីបញ្ចប់អ្នកមីងបានផ្តែផ្តាំទៅកសិករដទៃទៀតថា នៅពេលដែលយើងលក់ទឹកត្នោតមិនអស់គួរកែច្នៃធ្វើទឹកខ្មេះតាមវិធីខាងលើ យើងអាចទុកហូបបានយូរ និងលក់ក៏បាន។

**ពាន សុខា**

# បទពិសោធន៍រៀបចំកសិដ្ឋានពហុប្រយោជន៍

កសិករ **គង់ ម៉ឿន** រស់នៅភូមិតាសូ ឃុំឧត្តមសូរិយា ស្រុកត្រាំកក់ ខេត្តតាកែវ ជាកសិករសហការជាមួយអង្គការសេដាក។ ក្រោយពីបានទទួលការបណ្តុះបណ្តាល និងធ្វើទស្សនកិច្ចសិក្សាកសិដ្ឋានរបស់កសិករនៅខេត្តព្រៃវែងមក គាត់មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការរៀបចំកសិដ្ឋានពហុប្រយោជន៍។

នៅឆ្នាំ ២០០២ គាត់បានសំរេចចិត្តរៀបចំកសិដ្ឋានពហុប្រយោជន៍ លើផ្ទៃដី ២៤ អារ ក្នុងគោលបំណង :

- ចង់ចិញ្ចឹមត្រីក្នុងស្រែ
- មានអុសដុត និងមានចំណីសំរាប់សត្វ
- មានជីធម្មជាតិប្រើគ្រប់គ្រាន់
- មានឈើហូបផ្លែសំរាប់ទៅអនាគត



ទិដ្ឋភាពកសិដ្ឋានពហុប្រយោជន៍របស់កសិករ គង់ ម៉ឿន

**១. សកម្មភាពសំខាន់ៗ ក្នុងការរៀបចំកសិដ្ឋាន :**

នៅឆ្នាំ ២០០១ គាត់ពុំទាន់បានរៀបចំកសិដ្ឋានទេ គឺគាត់បានសាកល្បងធ្វើស្រូវ ប.វ.ស លើផ្ទៃដី ៥ អារ ដោយបានទទួលផល ១៣០ គីឡូក្រាម (២.៧ តោនក្នុង ១ ហិកតា) ។ នៅឆ្នាំ ២០០៣ គាត់ចាប់ផ្តើមជីកប្រឡាយទំហំមាត់លើ ១.៥ ម៉ែត្រ បាតក្រោម ១ ម៉ែត្រ ជំរៅ ០.៥ ម៉ែត្រ។ គាត់ជីកស្រះចិញ្ចឹមត្រីទំហំ ៨៨ ម៉ែត្រក្រឡា ជំរៅ ១.៥ ម៉ែត្រ។ បន្ទាប់ពីជីកប្រឡាយ និងស្រះរួចគាត់ក៏បានដាំដំណាំមានដូចជា ស្វាយ ដូង ពពាយយក្ស សណ្តែកអង្រៃ ល្ពៅ ននោង ស្លឹកគ្រៃ ត្រកួន ចំណែកក្នុងស្រះ គាត់បានដាក់ត្រីចិញ្ចឹមដូចជាប្រភេទត្រីទីឡាព្យា កាបស កាបសាមញ្ញ សរុបចំនួន ៣០០ ក្បាល។ នៅក្នុងកសិដ្ឋានគាត់បែង ចែកផ្ទៃដី ១៦ អារ សំរាប់ធ្វើស្រូវ ប.វ.ស។

ក្នុងការរៀបចំកសិដ្ឋានគាត់វិនិយោគទៅលើការជីកស្រះ ជីកប្រឡាយ ដែលបង្ហាញជូននៅក្នុងតារាងខាងក្រោម :

| **ការវិនិយោគថវិកាផ្ទាល់ខ្លួន** | **ការវិនិយោគកំលាំងផ្ទាល់ខ្លួន** |
|---|---|
| - ជីកស្រះ ៨០០០ រៀល<br>- ទិញសណ្តែក ២ គីឡូក្រាម = ៥០០០ រៀល<br>- ទិញកូនត្រី ១៥ ០០០ រៀល<br>- ទិញកូនស្វាយ ១០០០០ រៀល | - ជីកប្រឡាយខ្លួនឯង ១០ ថ្ងៃ<br>- ដាំដុះដំណាំលើភ្លឺស្រែ ៤ ថ្ងៃ<br>- ការភ្ជួររាស់ស្ទូងដក ៥ ថ្ងៃ<br>- ការពង្រាបដី ៦ ថ្ងៃ |



ប្រព័ន្ធប្រឡាយព័ទ្ធជុំវិញកសិដ្ឋាន

ក្រោយពីបានរៀបចំកសិដ្ឋានហើយ នៅចុងឆ្នាំ ២០០៣ គាត់ទទួលបានផលដូចខាងក្រោម :

- ស្រូវ ៨០០ គីឡូក្រាម
- ត្រី ៧៥ ០០០ រៀល
- បន្លែ ១០ ០០០រៀល (សល់ពីបរិភោគ)
- មាន់ ២៥០ ០០០ រៀល

មិនត្រឹមតែបានទទួលនូវប្រាក់ចំណូលប៉ុណ្ណោះទេ ដីជាតិដីបរិស្ថាននៅក្នុងកសិដ្ឋានក៏ប្រែប្រួលដែរ ។ បច្ចុប្បន្ន ដីផុសល្អ មាន សត្វល្អិតរស់នៅ ដីមានពណ៌ខ្មៅ តាមរយៈការដាំសណ្តែកបាយភ្ជួរលុបនៅពេលដែលសណ្តែកចេញផ្កា និងដាក់ជីកំប៉ុស្ត ចំបើង ស្លឹកឈើ) ។ ក្នុងស្រែគឺ មានត្រី កង្កែប ។ល។ មានប្រព័ន្ធប្រឡាយសំរាប់បញ្ចេញបញ្ចូលទឹក មានស្រះសំរាប់ស្តុកទឹក ទុកនៅរដូវវស្សា ដែលអាចស្រោចស្រពនៅរដូវប្រាំង ពេលមានការដាំដុះបន្លែ និងដំណាំផ្សេងៗ ។ ជាពិសេសកសិដ្ឋាននេះ បានផ្តល់ផល ឱ្យគាត់បានជាច្រើនមុខ ។ លោកពូបានបញ្ជាក់ប្រាប់ថា ការអនុវត្តន៍បែបនេះទាមទារអោយយើងចេះបែងចែក ពេលវេលា ថវិកា ពលកម្មឱ្យបានត្រឹមត្រូវ ទើបកសិដ្ឋានរីកចំរើន ។ បច្ចុប្បន្ននេះ កសិករនៅក្នុងភូមិបានទទួលស្គាល់ថា គាត់ជាគ្រូ កសិករ ។

## ២. ផែនការសំរាប់អភិវឌ្ឍន៍កសិដ្ឋាន

ទៅថ្ងៃមុខ គាត់មានផែនការដាំដុះដំណាំឈើពហុប្រយោជន៍ជារបងរស់ ដាំដំណាំឈើហូបផ្លែ (ល្មុត ក្រូចឆ្មារ ដូង.....) ពង្រីកស្រះ លើកភ្លឺអោយធំ ដើម្បីធ្វើការដាំដុះដំណាំតាមភ្លឺស្រែ ស្តារប្រឡាយបន្ថែមសំរាប់ផ្ទុកទឹក និងបញ្ចេញបញ្ចូលទឹកសំរាប់ផ្លូវត្រីហែលពីស្រះមកស្រែ ។ ពេលដែលដីមានជីជាតិគ្រប់គ្រាន់ គាត់ឈានទៅរកការធ្វើស្រែឥតភ្ជួរដី ធ្វើយ៉ាងណាបង្កលក្ខខណ្ឌអោយក្លាយជាស្រែដែលមានការទាក់ទាញអារម្មណ៍អ្នកជិតខាងអោយមានគំនិតធ្វើដូចនេះ ។

**ស៊ុំ ណារ៉ុន**

# ថ្នាំពុល និងបញ្ហាសុខភាព

លោកពូ **ឈួត ឈុំ** មានអាយុ ៧១ ឆ្នាំ ជាកសិកររស់នៅភូមិត្រពាំងទឹម ឃុំព្រីងជ្រុំ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ គាត់មានសមាជិកគ្រួសារចំនួន ៧ នាក់ មានមុខរបរធ្វើស្រែ។ គាត់មានជំងឺសើរស្បែករយៈពេល ២០ ឆ្នាំមកហើយ (ជំងឺហាង្សសិន)។ ជំងឺនេះមានអាការៈធ្ងន់ធ្ងរក្នុងរយៈពេល ៣-៤ ឆ្នាំ ចុងក្រោយនេះ។ នៅពេលដែលជំងឺគាត់រើម្តងៗ ធ្វើឱ្យគាត់រមាស់ពេញទាំងខ្លួន អេះដាច់ស្បែក។ ចំណែកឯក្មួយរបស់គាត់ក៏មានជំងឺដូចជាគាត់ដែរ។ ក្មួយរបស់គាត់បានដំណាលប្រាប់គាត់ថាខ្លួនធ្លាប់ប្រើថ្នាំពុលកំចាត់សត្វល្អិតយកមកលាបលើស្បែកនៅពេលរមាស់ (ថ្នាំរូបទង់ជ័យក្រហម) តែគាត់ធ្លាប់ពុលធ្ងន់ធ្ងរដោយសារលាបថ្នាំពុលនេះ។



រូបថតលោកពូ ឈួត ឈុំ ដែលបានទទួលមរណៈភាព

ថ្ងៃមួយដោយជំងឺរបស់លោកពូរើរមាស់ខ្លាំង គាត់ក៏បានឱ្យកូនទៅទិញថ្នាំទង់ជ័យក្រហមនោះមកលាប។ កូនរបស់គាត់បានប្រាប់គាត់ដែរថា ថ្នាំនេះពុលតែគាត់ពុំជឿក៏បានយកថ្នាំពុលនេះមកចាក់ចូលក្នុងកែវស្រា ហើយយកសំឡីជ្រលក់ពូតជូតលើស្បែក កន្លែងរមាស់ខ្លាំង ជាពិសេសស នៅលើជើង ដៃ ទ្រូង និងខ្លួនខ្លះៗ។ ក្រោយពីលាបហើយភ្លាមគាត់ចាប់ផ្តើមក្តៅក្រហាយ ហើយប្រកាច់កន្លះម៉ោងក្រោយមកទៀតចាប់រាកចំនួន ២ ដង ក្អួត ៣ ដង និងខ្លួនមានអាការៈស្លេកស្លាំង មានហូរទឹកមាត់ និងស្លេស៍តាមច្រមុះ។ រយៈពេល ១ ម៉ោង ក្រោយពីក្អួត គាត់សន្លប់លែងដឹងខ្លួន។ នៅពេលសន្លប់ ក្រុមគ្រួសារបានទៅតាមពេទ្យមកព្យាបាល។ រយៈពេល ២ ម៉ោង ក្រោយព្យាបាល គាត់ដឹងខ្លួនឡើងវិញ និយាយបានតិចៗថា ឈឺក្បាល ឈឺទ្រូង កន្ត្រាក់សាច់ដុំ ហើយសន្លប់បាត់ស្មារតីរយៈពេល ៣ថ្ងៃ បន្តទៀត។ ដល់ថ្ងៃទី ៤ គាត់ដឹងខ្លួនឡើងវិញ តែមានអាការៈកាន់តែធ្ងន់ធ្ងរឡើង គឺចាប់ផ្តើមរាក ដកដង្ហើមដង្ហក់ មានស្លេស៍តាមមាត់ និយាយបានខ្សាវៗ ហើយ ១០ នាទីក្រោយមកលោកពូក៏បានស្លាប់បាត់បង់ជីវិតទៅ។

នេះជាបទពិសោធន៍ដ៏អាក្រក់មួយដែលបងប្អូនកសិករគួរចងចាំ និងមានស្មារតីប្រុងប្រយ័ត្នលើការប្រើប្រាស់ថ្នាំពុលសំលាប់សត្វល្អិត ទោះក្នុងករណីណាក៏ដោយ។ ទាំងការប្រើប្រាស់លើដំណាំ ទាំងការប្រើក្នុងករណីផ្សេងៗ។ ត្រូវជួបជាមួយគ្រូពេទ្យដើម្បីពិគ្រោះជំងឺ កុំចេះតែប្រើប្រាស់ដោយស្មានខ្លួនឯង។ យកល្អ សូមបងប្អូនកសិករបញ្ឈប់ការប្រើប្រាស់ថ្នាំពុលកសិកម្ម ជៀសវាងការពុលដល់សុខភាព បរិស្ថាន និងមិនចំណាយអស់ថវិកាក្នុងគ្រួសារ។

**ឈុន វណ្ណាឌី**

# វិធីព្យាបាលមុនតាមបែបធម្មជាតិ

ប្អូនៗ យុវវ័យភាគច្រើន ច្រើនកើតមុននៅលើផ្ទៃមុខ ដែលធ្វើឱ្យបាត់បង់នូវសំរស់ធម្មជាតិ។ ដូច្នេះសូមប្អូនៗ កុំព្រួយបារម្ភ យើងមានវិធីព្យាបាលបែបសាមញ្ញដែលមិនចំណាយថវិកាច្រើនឡើយ ។

ខាងក្រោមនេះជាវិធីព្យាបាលតាមបែបធម្មជាតិមួយចំនួន ហើយប្អូនៗអាចជ្រើសរើសវិធីណាមួយ ដែលសមស្របសំរាប់ប្អូន :

វិធីទី១ : លាងមុខដោយសាប៊ូធម្មតាអោយស្អាត ហើយប្រើទឹកក្រូចឆ្មារលាយជាមួយទឹកអោយបានស្មើគ្នា មកលាបមុខអោយសព្វហើយលាងដោយទឹកស្អាតចេញវិញ ធ្វើអោយបានមួយថ្ងៃម្តង ។

វិធីទី២ : យកទឹករំអិលប្រទាលកន្ទុយក្រពើលាបមុខអោយសព្វដោយមិនបាច់លាងចេញទេ ព្រោះទឹករំអិលនេះនឹងស្ងួតដោយខ្លួនឯងក្នុងរយៈពេល ៥-១០នាទី។ មួយថ្ងៃធ្វើពីរលើកគឺពេលព្រឹក និងមុនពេលចូលដេក ហើយបើចង់លាងទឹករំអិលចេញ យើងគួរលាបទុកចោលយ៉ាងតិចអោយបាន ២០ នាទី ។

វិធីទី៣ : ប្រើស៊ុតមាន់យកតែស៊ុតសមកលាបស្តើងៗត្រង់បរិវេណដែលកើតមុន បន្ទាប់មកយកក្រដាសជូតមុខដាក់សង្កត់ពីលើទុកចោលប្រហែល ១៥ នាទី ទើបទាញយកក្រដាសជូតមុខនោះចេញ ពេលនោះគ្រាប់មុន និងចំណែកខ្ទុះនឹងរបូតចេញមកជាមួយ ។

វិធីទី៤ : ប្រើអំពិលទុំលាយជាមួយទឹកមកលាងមុខម្តងម្កាល វានឹងជួយធ្វើអោយមុខស្អាតស្រស់ថ្លា ឬក្រោយពីងូតទឹកហើយយកទឹកអំពិលមកលាបលើផ្ទៃមុខទុកចោល ១០-១៥ នាទី សឹមលាងចេញ។ ធ្វើដូចនេះអោយបាន ២ ដង ( ព្រឹក-ល្ងាច) វាជួយអោយផ្ទៃមុខប្រាសចាកពីមុន និងជាំមុខ ។

វិធីទី៥ : យកម្សៅរមៀតម៉ដ្តលាយទឹក ហើយលាយជាមួយទឹកឃ្មុំលាបបរិវេណកន្លែងកើតមុនទុក ១-១៥ នាទី ហើយយកទឹកអំពិលលាងសម្អាតចេញ។ ធ្វើដូចនេះមួយថ្ងៃម្តងរហូតទាល់តែជាមុន ។

វិធីទី៦ : យកខ្ទឹមសកន្លះកំពឹសបុកច្របល់ក្នុងត្បាល់អោយម៉ដ្ឋ ហើយមុនដេកយើងលាបត្រង់បរិវេណកើតមុន ពេលព្រឹកក្រោកពីដេកលាងវាចេញ ឬធ្វើរៀងរាល់ថ្ងៃអោយបានរយៈពេល ៧-១០ នាទី។ វិធីនេះ សមស្របសំរាប់មុនគ្រាប់ធំៗដែលឆ្លងមេរោគនឹងមានអាការៈហើមធំៗ ផង ។

វិធីទី៧ : ប្រើទឹកអង្ករមកលាងមុខរាល់ពេលព្រឹក-ល្ងាច មុខនឹងធូរស្រាលជាបណ្តើរៗ ហើយនឹងជាបាត់ ប៉ុន្តែត្រូវអត់ទ្រាំក្លិនស្អុយ អាក្រក់បន្តិច ព្រោះទឹកអង្ករពេលខ្លះមានក្លិនស្អុយជូរផងដែរ ។

វិធីទី៨ : យកទឹកដែលច្របាច់ចេញពីស្លឹកបាសមកលាបត្រង់ក្បាលមុនអោយបានញឹកញាប់ទុកចោល ៥-១០ នាទី ទើបលាងចេញឱ្យស្អាតវិញ ។

មុនកើតឡើងតាមបែបធម្មជាតិ ដូចនេះវិធីព្យាបាលតាមបែបធម្មជាតិគឺសមស្របបំផុត ហើយវាផ្តល់ទាំងភាពងាយស្រួលសុវត្ថិភាព មិនតមចំណីអារហារ និងមិនចំណាយថវិកាច្រើនទៀតផង ។

**ម៉ៅ តូចភ័ក្ត្រា**

និស្សិតវិទ្យាស្ថានជាតិគ្រប់គ្រងឆ្នាំទី៣

**ប្រភព:** កាសែតរស្មីកម្ពុជា

ក្នុងការរៀបចំកសិដ្ឋានគាត់វិនិយោគទៅលើការជីកស្រះ ជីកប្រឡាយ ដែលបង្ហាញជូននៅក្នុងតារាងខាងក្រោម :

| **ការវិនិយោគថវិកាផ្ទាល់ខ្លួន** | **ការវិនិយោគកំលាំងផ្ទាល់ខ្លួន** |
|---|---|
| - ជីកស្រះ ៨០០០ រៀល<br>- ទិញសណ្តែក ២ គីឡូក្រាម = ៥០០០ រៀល<br>- ទិញកូនត្រី ១៥ ០០០ រៀល<br>- ទិញកូនស្វាយ ១០០០០ រៀល | - ជីកប្រឡាយខ្លួនឯង ១០ ថ្ងៃ<br>- ដាំដុះដំណាំលើភ្លឺស្រែ ៤ ថ្ងៃ<br>- ការភ្ជួររាស់ស្ទូងដក ៥ ថ្ងៃ<br>- ការពង្រាបដី ៦ ថ្ងៃ |



ប្រព័ន្ធប្រឡាយព័ទ្ធជុំវិញកសិដ្ឋាន

ក្រោយពីបានរៀបចំកសិដ្ឋានហើយ នៅចុងឆ្នាំ ២០០៣ គាត់ទទួលបានផលដូចខាងក្រោម :

- ស្រូវ ៨០០ គីឡូក្រាម
- ត្រី ៧៥ ០០០ រៀល
- បន្លែ ១០ ០០០រៀល (សល់ពីបរិភោគ)
- មាន់ ២៥០ ០០០ រៀល

មិនត្រឹមតែបានទទួលនូវប្រាក់ចំណូលប៉ុណ្ណោះទេ ដីជាតិដីបរិស្ថាននៅក្នុងកសិដ្ឋានក៏ប្រែប្រួលដែរ ។ បច្ចុប្បន្ន ដីផុសល្អ មាន សត្វល្អិតរស់នៅ ដីមានពណ៌ខ្មៅ តាមរយៈការដាំសណ្តែកបាយ ភ្ជួរលុបនៅពេលដែលសណ្តែកចេញផ្កា និងដាក់ជីកំប៉ុស្ត ចំបើង ស្លឹកឈើ) ។ ក្នុងស្រែគឺ មានត្រី កង្កែប ។ល។ មានប្រព័ន្ធប្រឡាយសំរាប់បញ្ចេញបញ្ចូលទឹក មានស្រះសំរាប់ស្តុកទឹក ទុកនៅរដូវវស្សា ដែលអាចស្រោចស្រពនៅរដូវប្រាំង ពេលមានការដាំដុះបន្លែ និងដំណាំផ្សេងៗ។ ជាពិសេសកសិដ្ឋាននេះ បានផ្តល់ផល ឱ្យគាត់បានជាច្រើនមុខ ។ លោកពូបានបញ្ជាក់ប្រាប់ថា ការអនុវត្តន៏បែបនេះទាមទារអោយយើងចេះបែងចែក ពេលវេលា ថវិកា ពលកម្មឱ្យបានត្រឹមត្រូវទើបកសិដ្ឋានរីកចំរើន ។ បច្ចុប្បន្ននេះ កសិករនៅក្នុងភូមិបានទទួលស្គាល់ថា គាត់ជាគ្រូ កសិករ ។

## ២. ផែនការសំរាប់អភិវឌ្ឍន៍កសិដ្ឋាន

ទៅថ្ងៃមុខ គាត់មានផែនការដាំដុះដំណាំឈើពហុប្រយោជន៍ជារបងរស់ ដាំដំណាំឈើហូបផ្លែ (ល្មុត ក្រូចឆ្មារ ដូង.....) ពង្រីកស្រះ លើកភ្លឺអោយធំ ដើម្បីធ្វើការដាំដុះដំណាំតាមភ្លឺស្រែ ស្តារប្រឡាយបន្ថែមសំរាប់ផ្ទុកទឹក និងបញ្ចេញបញ្ចូលទឹកសំរាប់ផ្លូវត្រីហែលពីស្រះមកស្រែ ។ ពេលដែលដីមានជីជាតិគ្រប់គ្រាន់ គាត់ឈានទៅរកការធ្វើស្រែឥតភ្ជួរដី ធ្វើយ៉ាងណាបង្កលក្ខខណ្ឌអោយក្លាយជាស្រែដែលមានការទាក់ទាញអារម្មណ៍អ្នកជិតខាងអោយមានគំនិតធ្វើដូចនេះ ។

**អ៊ុំ ណារ៉ុន**

# ថ្នាំពុល និងបញ្ហាសុខភាព

លោកពូ **ឈួត ញ៉ុំ** មានអាយុ ៧១ ឆ្នាំ ជាកសិកររស់នៅភូមិត្រពាំងទឹម ឃុំព្រីងជ្រុំ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ គាត់មានសមាជិកគ្រួសារចំនួន ៧ នាក់ មានមុខរបរធ្វើស្រែ។ គាត់មានជំងឺសើរស្បែករយៈពេល ២០ ឆ្នាំមកហើយ (ជំងឺហង្សសិន)។ ជំងឺនេះមានអាការៈធ្ងន់ធ្ងរក្នុងរយៈពេល ៣-៤ ឆ្នាំ ចុងក្រោយនេះ។ នៅពេលដែលជំងឺគាត់រើម្តងៗ ធ្វើឱ្យគាត់រមាស់ពេញទាំងខ្លួន អេះដាច់ស្បែក។ ចំណែកឯក្មួយរបស់គាត់ក៏មានជំងឺដូចជាគាត់ដែរ។ ក្មួយរបស់គាត់បានដំណាលប្រាប់គាត់ថា ខ្លួនធ្លាប់ប្រើថ្នាំពុលកំចាត់សត្វល្អិតយកមកលាបលើស្បែកនៅពេលរមាស់ (ថ្នាំរូបទង់ជ័យក្រហម) តែគាត់ធ្លាប់ពុលធ្ងន់ធ្ងរដោយសារលាបថ្នាំពុលនេះ។



រូបថតលោកពូ ឈួត ញ៉ុំ ដែលបានទទួលមរណភាព

ថ្ងៃមួយដោយជំងឺរបស់លោកពូរើរមាស់ខ្លាំង គាត់ក៏បានឱ្យកូនទៅទិញថ្នាំទង់ជ័យក្រហមនោះមកលាប។ កូនរបស់គាត់បានប្រាប់គាត់ដែរថា ថ្នាំនេះពុលតែគាត់ពុំជឿក៏បានយកថ្នាំពុលនេះមកចាក់ចូលក្នុងកែវស្រា ហើយយកសំឡីជ្រលក់ពូតជូតលើស្បែក កន្លែងរមាស់ខ្លាំង ជាពិសេសស នៅលើជើង ដៃ ទ្រូង និងខ្លួនខ្លះៗ។ ក្រោយពីលាបហើយភ្លាមគាត់ចាប់ផ្តើមក្តៅក្រហាយ ហើយប្រកាច់កន្លះម៉ោងក្រោយមកទៀតចាប់រាកចំនួន ២ ដង ក្អួត ៣ ដង និងខ្លួនមានអាការៈស្លេកស្លាំង មានហូរទឹកមាត់ និងស្លេស៍តាមច្រមុះ។ រយៈពេល ១ ម៉ោង ក្រោយពីក្អួត គាត់សន្លប់លែងដឹងខ្លួន។ នៅពេលសន្លប់ ក្រុមគ្រួសារបានទៅតាមពេទ្យមកព្យាបាល។ រយៈពេល ២ ម៉ោង ក្រោយព្យាបាល គាត់ដឹងខ្លួនឡើងវិញ និយាយបានតិចៗថា ឈឺក្បាល ឈឺទ្រូង កន្ទ្រាក់សាច់ដុំ ហើយសន្លប់បាត់ស្មារតីរយៈពេល ៣ថ្ងៃ បន្តទៀត។ ដល់ថ្ងៃទី ៤ គាត់ដឹងខ្លួនឡើងវិញ តែមានអាការៈកាន់តែធ្ងន់ធ្ងរឡើង គឺចាប់ផ្តើមរាក ដកដង្ហើមដង្ហក់ មានស្លេស៍តាមមាត់ និយាយបានខ្សាវៗ ហើយ ១០ នាទីក្រោយមកលោកពូក៏បានស្លាប់បាត់បង់ជីវិតទៅ។

នេះជាបទពិសោធន៍ដ៏អាក្រក់មួយដែលបងប្អូនកសិករគួរចងចាំ និងមានស្មារតីប្រុងប្រយ័ត្នលើការប្រើប្រាស់ថ្នាំពុលសំលាប់សត្វល្អិត ទោះក្នុងករណីណាក៏ដោយ។ ទាំងការប្រើប្រាស់លើដំណាំ ទាំងការប្រើក្នុងករណីផ្សេងៗ។ ត្រូវជួបជាមួយគ្រូពេទ្យដើម្បីពិគ្រោះជំងឺ កុំចេះតែប្រើប្រាស់ដោយស្មានខ្លួនឯង។ យកល្អ សូមបងប្អូនកសិករបញ្ឈប់ការប្រើប្រាស់ថ្នាំពុលកសិកម្ម ជៀសវាងការពុលដល់សុខភាព បរិស្ថាន និងមិនចំណាយអស់ថវិកាក្នុងគ្រួសារ។

**ឈុន វណ្ណធី**

# ១៨ វិធីព្យាបាលមុនតាមបែបធម្មជាតិ

ប្អូនៗ យុវវ័យភាគច្រើន ច្រើនកើតមុននៅលើផ្ទៃមុខ ដែលធ្វើឱ្យបាត់បង់នូវសំរស់ធម្មជាតិ។ ដូច្នេះសូមប្អូនៗ កុំព្រួយបារម្ភ យើងមានវិធីព្យាបាលបែបសាមញ្ញដែលមិនចំណាយថវិកាច្រើនឡើយ។

ខាងក្រោមនេះជាវិធីព្យាបាលតាមបែបធម្មជាតិមួយចំនួន ហើយប្អូនៗអាចជ្រើសរើសវិធីណាមួយ ដែលសមស្របសំរាប់ប្អូន :

<u>វិធីទី១</u> : លាងមុខដោយសាប៊ូធម្មតាអោយស្អាត ហើយប្រើទឹកក្រូចឆ្មារលាយជាមួយទឹកអោយបានស្មើគ្នា មកលាបមុខអោយសព្វហើយលាងដោយទឹកស្អាតចេញវិញ ធ្វើអោយបានមួយថ្ងៃម្តង។

<u>វិធីទី២</u> : យកទឹករំអិលប្រទាលកន្ទុយក្រពើលាបមុខអោយសព្វដោយមិនបាច់លាងចេញទេ ព្រោះទឹករំអិលនេះនឹងស្ងួតដោយខ្លួនឯងក្នុងរយៈពេល ៥-១០នាទី។ មួយថ្ងៃធ្វើពីរលើកគឺពេលព្រឹក និងមុនពេលចូលដេក ហើយបើចង់លាងទឹករំអិលចេញ យើងគួរលាបទុកចោលយ៉ាងតិចអោយបាន ២០ នាទី។

<u>វិធីទី៣</u> : ប្រើស៊ុតមាន់យកតែស៊ុតសមកលាបស្តើងៗត្រង់បរិវេណដែលកើតមុន បន្ទាប់មកយកក្រដាសជូតមុខដាក់សង្កត់ពីលើទុកចោលប្រហែល ១៥ នាទី ទើបទាញយកក្រដាសជូតមុខនោះចេញ ពេលនោះគ្រាប់មុន និងចំណែកខ្លះនឹងរបូតចេញមកជាមួយ។

<u>វិធីទី៤</u> : ប្រើអំពិលទុំលាយជាមួយទឹកមកលាងមុខម្តងម្កាល វានឹងជួយធ្វើអោយមុខស្អាតស្រស់ថ្លា ឬក្រោយពីងូតទឹកហើយយកទឹកអំពិលមកលាបលើផ្ទៃមុខទុកចោល ១០-១៥ នាទី សឹមលាងចេញ។ ធ្វើដូចនេះអោយបាន ២ ដង (ព្រឹក-ល្ងាច) វាជួយអោយផ្ទៃមុខប្រាសចាកពីមុន និងជាំមុខ។

<u>វិធីទី៥</u> : យកម្សៅរមៀតម៉ដ្ឋលាយទឹក ហើយលាយជាមួយទឹកឃ្មុំលាបបរិវេណកន្លែងកើតមុនទុក ១-១៥ នាទី ហើយយកទឹកអំពិលលាងសម្អាតចេញ។ ធ្វើដូចនេះមួយថ្ងៃម្តងរហូតទាល់តែជាមុន។

<u>វិធីទី៦</u> : យកខ្ទឹមសកន្លះកំពឹសបុកច្របល់ក្នុងត្បាល់អោយម៉ដ្ឋ ហើយមុនដេកយើងលាបត្រង់បរិវេណកើតមុន ពេលព្រឹកក្រោកពីដេកលាងវាចេញ ឬធ្វើរៀងរាល់ថ្ងៃអោយបានរយៈពេល ៧-១០ នាទី។ វិធីនេះ សមស្របសំរាប់មុនគ្រាប់ធំៗដែលឆ្លងមេរោគនិងមានអាការៈហើមធំៗ ផង។

<u>វិធីទី៧</u> : ប្រើទឹកអង្ករមកលាងមុខរាល់ពេលព្រឹក-ល្ងាច មុខនឹងធូរស្រាលជាបណ្តើរៗ ហើយនឹងជាបាត់ ប៉ុន្តែត្រូវអត់ទ្រាំក្លិនស្អុយ អាក្រក់បន្តិច ព្រោះទឹកអង្ករពេលខ្លះមានក្លិនស្អុយជួរផងដែរ។

<u>វិធីទី៨</u> : យកទឹកដែលច្របាច់ចេញពីស្លឹកបាសមកលាបត្រង់ក្បាលមុនអោយបានញឹកញាប់ទុកចោល ៥-១០ នាទី ទើបលាងចេញឱ្យស្អាតវិញ។

មុនកើតឡើងតាមបែបធម្មជាតិ ដូចនេះវិធីព្យាបាលតាមបែបធម្មជាតិគឺសមស្របបំផុត ហើយវាផ្តល់ទាំងភាពងាយស្រួលសុវត្ថិភាព មិនតមចំណីអាហារ និងមិនចំណាយថវិកាច្រើនទៀតផង។

**ម៉ៅ គួចភ័ក្ត្រា**
និស្សិតវិទ្យាស្ថានជាតិគ្រប់គ្រងឆ្នាំទី៣

ប្រភព: កាសែតរស្មីកម្ពុជា

## កំណាព្យ

### បញ្ហាថ្នាំពុល

កសិករខ្មែរ នាំគ្នាគួរកែ ប្រួលប្រែគំនិត
ត្រូវពិចារណា រិះរកការពិត តាមដានពិនិត្យ
ថាមកពីអ្វី ។

កាលពីដូនតា ដីស្រែចំការ គ្មានបញ្ហាអី
ដំណាំដាំដុះ ផុលផុសខៀវខ្ចី ប្រជាប្រុសស្រី
ប្រើជីធម្មជាតិ ។

ផលដែលបានមក ទុកដាក់គគោក ទាំងស្រូវអង្ករ
បន្លែផ្លែឈើ ខ្ចីទុំបវរ ត្រីសាច់នោះក៏
បរិសុទ្ធគ្មានពុល ។

ទាំងមនុស្សសត្វ រស់គ្មានវិបត្តិ បរិស្ថានល្អស្រស់
ទឹកដីភ្លើងខ្យល់ បរិសុទ្ធឥតខ្ចោះ មនុស្សសត្វទាំងអស់
សុខភាពមាំមួន ។

យើងឃើញហើយថា ដើមឡើយដូនតា រស់គ្មានរោគា
អាយុយឺនយូរ សំបូរធូរធារ គ្មានអស់ទ្រព្យា
ចាយលើថ្នាំពេទ្យ ។

ចុះឥឡូវនេះ មនុស្សកាន់តែចេះ អភិវឌ្ឍន៍ខ្លាំងក្លា
ប្រែក្លាយទឹកដី ខុសពីធម្មតា វិលវិចខ្លោចផ្សារ
ព្រោះប្រើថ្នាំពុល ។

គួរពិចារណា នូវម្ហូបអាហារ ភោគ្គារាល់ថ្ងៃ
សុទ្ធតែជាតិពុល លុកលុយប្រល័យ រស់ដោយភិតភ័យ
រោគាពេញប្រាណ ។

ទាំងស្រូវអង្ករ បន្លែគ្រឿងស្ល ប្រហុកផ្អកមាំ
ប៊ីចេងថ្នាំជក់ ហូបជាប្រចាំ ទឹកផឹកក៏ថ្នាំ
ទាំងខ្យល់អាកាស ។

**ចំណីត្រីសាច់** ដាក់កំប៉ុងស្រេច ឬដបតូចធំ
ទឹកក្រូចឬស្រា ត្រៀបត្រាដូចភ្នំ ទាំងគេទាំងខ្ញុំ
ធ្វើឯងហ៊ឺហា ។

គ្មានគិតដល់សោះ របស់ទាំងអស់ នេះជាគីមី
លេបចូលកាលណា រុករានញ៉ាំញី សួតថ្លើមខ្ទេចខ្ទី
រួមក្រពះផង ។

ស្ពឹកជើងស្ពឹកដៃ ឆ្អឹងសាច់សរសៃ ខុសពីធម្មតា
រត់ទិញថ្នាំពេទ្យ អស់ទាំងទ្រព្យា លេបចាក់មិនជា
ខ្លួនក៏ក្សិនក្ស័យ ។

មើលពូជសត្វវិញ ដើមឡើយពាសពេញ សំបូរច្រើនក្រៃ
ក្នុងទឹកលើគោក ខ្សៀវខ្សាពេញព្រៃ ឥឡូវខ្លះក្ស័យ
ខ្លះរត់គេចអស់ ។

ខ្ញុំសូមអង្វរ ដល់ពាណិជ្ជករ ក្រុមហ៊ុនផលិត
លួមឈប់បង្កើត ថ្នាំពុលឧក្រិដ្ឋ ប្រល័យជីវិត
មនុស្សសត្វលោក ។

រួមគ្នាកំចាត់ កុំទុកវិបត្តិ តកូនតចៅ
ក្មេងជេរដៀលថា ដូនតាល្ងង់ខ្លៅ បន្សល់ទុកនៅ
វិនាសខ្លោចផ្សារ ។

ខ្ញុំយ៉ង់សាមី មិនសូវសំភី ចំណេះវិជ្ជា
ចេះតិចតួចណាស់ តែងកាព្យឃ្លោងឃ្លា ខុសត្រូវម្តេចម្តា
ថែមថយឱ្យផង ។

កសិករ **យ៉ង់ សាមី**
ភូមិឃ្លាំង ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង

# ពិធីសម្ពោធមជ្ឈមណ្ឌលធនធានឯកសារកសិករនៅស្រុកត្រាំកក់ ខេត្តតាកែវ

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ហៅកាត់ថា (អង្គការសេដាក) បានបើកពិធីសម្ពោធមជ្ឈមណ្ឌលធនធានឯកសារកសិករនៅស្រុកត្រាំកក់ចំនួន ៣ កន្លែង នៅវត្តបន្ទាយចមពល វត្តឧត្តមសូរិយា និងវត្តមង្គលមានល័ក្ខ។ កាលពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០៤ កន្លងទៅនេះ មានការបើកសម្ពោធឱ្យប្រើប្រាស់ជាផ្លូវការ មជ្ឈមណ្ឌលធនធានឯកសារនៅវត្តឧត្តមសូរិយាដែលមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម **សូ ឃុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បណ្ឌិត **យ៉ង សាំងកុមារ** នាយកប្រតិបត្តិអង្គការសេដាក និងលោក **យារ៉ាគូជី អាគីហ៊ីរ៉ា** ទីប្រឹក្សាអង្គការ (JICA) ព្រមទាំងបុគ្គលិកសេដាក និងកសិករជាច្រើនទៀត។

មជ្ឈមណ្ឌលនេះសាងសង់ឡើងក្នុងគោលបំណង :

- ជាកន្លែងសំរាប់ជួបជុំកសិករ ពង្រឹងសមត្ថភាពកសិករ និងអ្នកពាក់ព័ន្ធ
- ជាកន្លែងសំរាប់តំកល់ឯកសារទុកឱ្យកសិករអាន និងស្រាវជ្រាវ
- ជាកន្លែងលក់ផលិតផលកសិកម្ម និងសិប្បកម្មសំរាប់កសិករ
- ជាកន្លែងសំរាប់តាំងពិពណ៌ផលិតផល និងសំភារៈកសិកម្មរបស់កសិករ



ឯកឧត្តម ចាន់ សារុន
កាត់ខ្សែបូរសម្ពោធអាគារមជ្ឈមណ្ឌលធនធានឯកសារកសិករ

ក្នុងពិធីសម្ពោធនេះ ឯកឧត្តម **ច័ន្ទ សារុន** បានមានប្រសាសន៍ថា អង្គការសេដាកជាដៃគូដ៏ជិតស្និទ្ធរបស់ក្រសួងកសិកម្ម ក្នុងការងារអភិវឌ្ឍន៍កសិកម្ម ជាពិសេស កសិកម្មជាលក្ខណៈគ្រួសារ ឱ្យកសិករមានហូបចុកគ្រប់គ្រាន់ និងមាននិរន្តរភាពយូរ អង្វែង។





មជ្ឈមណ្ឌលធនធានឯកសារកសិករ

យី គឹមថាន

# តំលៃផលិតផលកសិកម្មលើទីផ្សារក្រុងភ្នំពេញ

## ខែសីហា ឆ្នាំ ២០០៤

| អង្ករ | តំលៃលក់ដុំ | តំលៃលក់រាយ | ត្រី-សាច់ | តំលៃលក់ដុំ | តំលៃលក់រាយ |
|---|---|---|---|---|---|
| សុមាលី | ១៤០០ | ១៥០០ | ត្រីរ៉ស់ធំ | ៨០០០ | ៩០០០ |
| ផ្កាម្លិះ | ១៤៨០ | ១៦០០ | ត្រីឆ្តោរធំ | ១១០០០ | ១២០០០ |
| ផ្កាខ្ញី | ១១៥០ | ១៣០០ | ត្រីសណ្តាយ | ១៦០០០ | ២០០០០ |
| នាងខុន | ១១០០ | ១២០០ | ត្រីឆ្លាំង | ៨០០០ | ១០០០០ |
| នាងម៉ិញ | ១០៨០ | ១២០០ | ត្រីដីរ | ៩០០០ | ១០០០០ |
| ក្រោកពង្ស | ៩៥០ | ១៣០០ | ត្រីដៀប | ១០៧០០ | ១២០០០ |
| ឆ្មារព្រហ្ម | ៩៨០ | ១៣៥០ | សាច់មាន់ | ៩៥០០ | ១០០០០ |
| បន្ទាផ្តៅ | ៩៨០ | ១០០០ | សាច់ទា | ៦៥០០ | ៧០០០ |
| ដំណើបស | ១០៨០ | ១៣០០ | សាច់គោលេខមួយ | ១៥០០០ | ១៧០០០ |
| ដំណើបខ្មៅ | ១៦០០ | ១៧០០ | សាច់ជ្រូកលេខមួយ | ៩០០០ | ៩៥០០ |
| **បន្លែផ្លែ - មើម** | **តំលៃលក់ដុំ** | **តំលៃរាយ** | **បន្លែស្លឹក** | **តំលៃលក់ដុំ** | **តំលៃរាយ** |
| ប៉េងប៉ោះ | ១៤០០ | ១៦០០ | សាលាដ់ | ១៥០០ | ១៦៥០ |
| ម្ទេសហាវ៉ៃ | ២៣០០ | ២៥០០ | ខាត់ណា | ១៣៥០ | ១៦០០ |
| ត្រសក់ | ៧០០ | ៨០០ | ផ្កាខាត់ណា | ៣៣០០ | ៣៥០០ |
| សណ្តែកបារាំង | ១៣០០ | ១៤០០ | ស្ពៃក្តោប | ៩៥០ | ១២០០ |
| សណ្តែកកួរ | ១៣០០ | ១៥០០ | ស្ពៃចង្កឹះ | ៧០០ | ១០០០ |
| ម្រះ | ១៤០០ | ១៦៥០ | ស្ពៃក្រញាញ់ | ១០០០ | ១៣៥០ |
| ត្រប់ស្រួយ | ៦០០ | ១០០០ | ស្ពៃប៉ាក់ចយ | ១៤០០ | ១៧០០ |
| ឆៃថាវ | ៦០០ | ១០០០ | តាំងអោ | ២៧៥០ | ៣០០០ |
| ប៉ុតគក់ | ៥០០ | ៨០០ | ជ្ជី | ១១៥០ | ១៤០០ |
| ត្រាវ | ១១០០ | ១៦០០ | ស្ពៃជ្រក់ | | |
| ដំឡូងជ្វា | ៦៥០ | ១០០០ | ខ្ទឹមស្លឹក | ១១០០ | ១៤០០ |
| ដំឡូងដូង | ៧០០ | ១០០០ | ផ្កាគូឆាយ | ២០៥០ | ២២០០ |
| ការ៉ុត | ១៨០០ | ២២០០ | ស្លឹកគូឆាយ | ១៣០០ | ១៥០០ |
| ខ្ទឹមបារាំង | ២០០០ | ២៣៥០ | ជីគ្រប់មុខ | ១៥៥០ | ១៨០០ |
| ខ្ញី | ២៧០០ | ៣០០០ | ផ្សិតចំបើង | ៧០០០ | ៨០០០ |

ប្រភព: ផ្សារដើមគរ, ផ្សារអូរឫស្សី, ផ្សារថ្មី

**គា គឹមសាន និងសែម បូធុម**



# និរន្តរភាពស្រះចិញ្ចឹម និង ទាក់ទាញត្រីធម្មជាតិ


- រៀបចំ និង បោះពុម្ពផ្សាយដោយ **មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា** (CEDAC)
- ពត៌មានផ្សេងៗ និងការបែងចែកផ្សព្វផ្សាយ សូមទំនាក់ទំនង លោកស្រី **ពាន សុខា**

  ផ្ទះលេខ ៣៩ ផ្លូវលេខ ៥២៨ សង្កាត់បឹងកក់ ១ ខ័ណ្ឌទួលគោក

  ប្រអប់សំបុត្រលេខ ១១១៨ រាជធានីភ្នំពេញ

  ទូរស័ព្ទ : (០២៣) ៨៨០៩១៦

  ទូរសារ : (០២៣) ៨៨៥ ១៤៦

  ***E.mail : Cedacrc@camnet.com.kh***
- ឧបត្ថម្ភថវិកាដោយ : អង្គការ **អុកស្វាមអង់គ្លេស *(OXFAM GB)***
- ស្ថាប័ន និងបុគ្គលផ្សេងទៀតដែលបានចូលរួមចំណែកដល់ការបោះពុម្ពផ្សាយ :
  - ឯកឧត្តម **ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
  - ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន
  - អង្គការ : ***CFSI, EED, JICA, JFPR/ADB, AFSC, PADEK, MCC, LWF, CRS, SCALE, CIDSE, CWS, SCIRP,*** បណ្ដុះកុមារ, វឌ្ឍនភាព